ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី ឃុំ ជ្រោយប្រស់

## ឆ្នាំ ២០០៩-២០២២

## ស្រុក កោះកុង ខេត្ត កោះកុង



**រៀបចំដោយៈ** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយៈ** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

## មាតិកា


**អារម្ភកថា** ........ ១

**សេចក្តីផ្តើម** ........ ២

**ជំពូក១: ព័ត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ........ ៤

**១.១ ស្ថានភាពទូទៅ** ........ ៤

១.១.១ ទីតាំងរដ្ឋបាល ........ ៤

១.១.២ ប្រជាសាស្ត្រ ........ ៥

១.១.៣ ភាពគ្មានដីធ្លី ........ ៦

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ........ ៦

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ........ ៧

១.១.៦ ស្ថានភាពសុខាភិបាល ........ ៨

១.១.៦.១ ផ្នែកសុខាភិបាល ........ ៨

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ........ ៩

**១.២ ស្ថានភាពភូមិសាស្ត្រ** ........ ១០

១.២.១ ទីតាំងភូមិសាស្ត្រ ........ ១០

១.២.២ អាកាសធាតុ ........ ១០

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ........ ១១

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ........ ១៣

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ........ ១៣

១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ........ ១៤

១.៣.៣ ផលិតកម្មកសិកម្ម ........ ១៤

១.៣.៤ ធនធានធម្មជាតិ ........ ១៨

១.៣.៤.១ ធនធានព្រៃឈើ ........ ១៨

១.៣.៤.២ ធនធានជលផល ........ ១៨

**១.៤ ទីផ្សារ និង ខ្សែសង្វាក់ផលិតផល** ........ ១៩

១.៤.១ ទីផ្សារ និង តម្លៃកសិផល ផល និង អនុផលព្រៃឈើ និងផលនេសាទ ........ ១៩

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ........ ១៩

១.៤.៣ ឱកាស ឧបសគ្គ ........ ១៩

**ជំពូក២: ការវិភាគពី ឧបសគ្គ តម្រូវការសំរាប់អនាគត និង សក្តានុពល** ........ ២០

**២.១ តំបន់រសើប** ........ ២០

**២.២ ការប្រឈម/ឧបស័គ្គ** ........ ២០

**២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំជ្រោយប្រស់** ........ ២១

**២.៤ តម្រូវការសំរាប់អនាគត** ........ ២២

២.៤.១ ប្រជាសាស្ត្រ ........ ២២

២.៤.១.១ អត្រាកំណើន ........ ២២

២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ........ ២៣

២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន ........ ២៣

២.៤.៣ តម្រូវការដីកសិកម្ម ........ ២៤

២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ........ ២៤

២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម ........ ២៥

២.៤.៥.១ តម្រូវការដីសាលារៀន ........ ២៥

២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ........ ២៦

២,៤,៥,៣ ផ្នែកវប្បធមិ និង សាសនា ........ ២៧

២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ........ ២៧

**ជំពូក៣: ផែនការប្រើប្រាស់ដីអនាគត** ........ ២៨

**៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី** ........ ២៨

៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ........ ២៨

៣.១.២ តម្រូវការដីតាមប្រភេទ ........ ២៩

**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ........ ៣០

៣.២.១ ការវិភាគអន្តរៈអំពើ ........ ៣០

៣.២.២ ផែនទីប្រើប្រាស់ដីអនាគត ........ ៣១

៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ........ ៣១

៣.២.៣.១ ដីលំនៅដ្ឋាន ( បញ្ញត្តិគោលការណ៍ការប្រើប្រាស់ដី ) ........ ៣៣

៣.២.៣.២ ដីចំការដំណាំ ........ ៣៤

៣.២.៣.៣ ការប្រើប្រាស់ទឹក និង ប្រព័ន្ធស្រោចស្រព ........ ៣៥

៣.២.៣.៤ ការប្រើប្រាស់ផ្លូវថ្នល់ ........ ៣៥

៣.២.៣.៥ ទីតាំងផ្លូវក្រាលគ្រួសក្រហមលេខកូដ F R D ៣-០១ ........ ៣៥

៣.២.៣.៦ ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ ........ ៣៦

៣.២.៣.៧ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន ........ ៣៦

ឧបសម្ព័ន្ធ១ : ការពិពណ៌នាអំពី ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន......................................៣៨
ឧបសម្ព័ន្ធ២ : ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីចុប្បន្ន................................................៤៤
ឧបសម្ព័ន្ធ៣ : បញ្ហាពាក់ពន្ធ័ក្នុងការប្រើប្រាស់ដី(បញ្ហា/មូលហេតុ/ដំណោះស្រាយ)..............៤៦
ឧបសម្ព័ន្ធ៤ : ក្របខណ្ឌអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត...............................៤៩
ឧបសម្ព័ន្ធ៥ : បញ្ជីគម្រោង ឬសកម្មភាពសំខាន់ៗរបស់ឃុំក្នុងរយៈពេល ១៥ ឆ្នាំ...............៥៣
ឧបសម្ព័ន្ធ៦ : ផែនទីប្រើប្រាស់ដីលំអិតក្នុងឃុំ
ឧបសម្ព័ន្ធ៧ : ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំ
ឧបសម្ព័ន្ធ៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគតក្នុងឃុំឆ្នាំ ២០០៩-២០២២

# អារម្ភកថា

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំជ្រោយប្រស់ ឆ្នាំ ២០០៩-២០២២ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំនិងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ចូលរួមជួយពីអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីស្រុកកោះកុង(D_LUP)សហការចូលរួមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីខេត្តកោះកុង (P_LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី (Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។

ការរៀបចំចងក្រងជាសៀវភៅនេះឡើងដើម្បីជាត្រីវិស័យក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ការប្រើប្រាស់ដីឱ្យចំទិសដៅដែលមានការផ្សារភ្ជាប់ទៅនឹងផែនការជាតិ អភិវឌ្ឍន៍សង្គមកិច្ច និង សេដ្ឋកិច្ចផងដែរ និងដើម្បីចូលរួមចំណែកការលើកកំពស់ជីវភាព ធានាសន្តិសុខស្បៀងព្រមទាំងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជាពិសេសនៅតាមតំបន់ជនបទដែលមានជីវភាពស្ទើរតែទាំងស្រុងពឹងផ្អែកលើធនធានធម្មជាតិ ។

ផែនការប្រើប្រាស់ដីធ្លី ដែលបានកសាងឡើងនេះមានសារៈសំខាន់ណាស់ក្នុងការជួយចង្អុលបង្ហាញទិសដៅដល់ការអភិវឌ្ឍន៍ឃុំឱ្យឆ្លើយតបទៅនឹងតំរូវការពិតប្រាកដរបស់ប្រជាពលរដ្ឋដើម្បីបង្កើនកំរិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង ។

ក្រុមប្រឹក្សាឃុំជ្រោយប្រស់សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និង អង្គការ DANIDA/DFID-NZAid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលបានផ្តល់ថវិកាជំនួយ សំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ ។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការនេះក៏អាចមិនទទួលភាពជោគជ័យផងដែរដរាបណាគ្មានការចូលរួមពីមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តរដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មខេត្ត និង មន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំជ្រោយប្រស់ក៏មិនអាចបំភ្លេចបានដែរ នូវការជួយឧបត្ថម្ភគាំទ្របង្ហាត់បង្ហាញទាំងទ្រឹស្តី និងបច្ចេកទេសផ្ទាល់ លើការរៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត ( PLUP ) ថ្នាក់ស្រុក ( DLUP ) និង ក្រុមការងារថ្នាក់ជាតិ ( N-LUP ) របស់សមាសភាគរៀបចំដែនដី ។

យើខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាព និង តំរូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយដែលពាក់ព័ន្ធ និងការប្រើប្រាស់ដីធ្លីដែលរាំងស្ទះដល់ដំណើការអភិវឌ្ឍន៍ឃុំជ្រោយប្រស់ ហើយនឹងបង្ហាញនូវទឹកចិត្តសប្បុរសធមិដ៏ថ្លៃថ្លាតាមរយៈការចូលរួមចំណែកផ្តល់នូវសំភារៈ និង ថវិកាសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីធ្លីនេះដើម្បីចូលរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និង សហវិមជ្ឈការរបស់រាជរដ្ឋាភិបាលប្រកបដោយ ជោគជ័យ ។

ធ្វើនៅជ្រោយប្រស់, ថ្ងៃទី២៥....ខែ............ឆ្នាំ ២០០៩

មេឃុំ

ពុំ ធឿន

# សេចក្តីផ្តើម

បច្ចុប្បន្ននេះមានគំរោងអភិវឌ្ឍន៍ជាច្រើនកំពុងដំណើរការក្នុងគោលបំណងផ្សេងៗគ្នា ដែលគំរោងអភិវឌ្ឍន៍ខ្លះពុំបានគិតដល់ការអភិរក្ស និង ការធ្វើសមាហរណកម្មផែនការដូចក្រុមប្រឹក្សាគោលនយោបាយដីធ្លីដែលបានបង្ហាញយ៉ាងច្បាស់អំពីកង្វះខាតក្នុងការធ្វើសមាហរណកម្មការកសាងផែនការប្រើប្រាស់ដី និង ការគ្រប់គ្រងធនធានធម្មជាតិដែលនាំឱ្យមានកើតឡើងនូវបញ្ហាយ៉ាងច្រើនដូចជា : ការកាប់ទន្ទ្រានព្រៃឈើតំបន់ការពារ ការសាងសង់លើទីតាំងការកាប់ឈើខុសច្បាប់ ការរំលោភយកដី និង លុបចោលនូវសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ សំរាប់ការចិញ្ចឹមជីវិត ។

ការកសាងផែនការប្រើប្រាស់ដីធ្លី បានចាត់ទុកជាមូលដ្ឋានគតិយុត្តិមួយសំរាប់ការអភិវឌ្ឍន៍ និង ការប្រើប្រាស់ដីក្នុងគោលបំណងបំរើផលប្រយោជន៍សាធារណៈ ។

ប្រព័ន្ធនៃការរៀបចំផែនប្រើប្រាស់ដីធ្លី គឺជាមធ្យោបាយការដ៏មានប្រសិទ្ធិភាពបំផុតដើម្បីឆ្លើយតបទៅនឹងតំរូវការអភិវឌ្ឍន៍កិច្ចការពារបរិស្ថាន និង ជាគន្លឹះមួយដែលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រកបដោយចិរភាពរបស់រាជរដ្ឋាភិបាល ដែលជួយដល់ការអភិវឌ្ឍន៍ចាំបាច់មួយចំនួននៅលើទីតាំងដីសមស្រប មិនបាត់បង់នូវធនធានធម្មជាតិសំរាប់កូនចៅជំនាន់ក្រោយ ។

ផែនការនេះនឹងបង្កើតឱ្យមានក្របខ័ណ្ឌច្បាស់លាស់ក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី និង ការវិនិយោគទូទៅផងដែរ ។ តួយ៉ាងឃុំជ្រោយប្រសជាឃុំមួយក្នុងចំណោមឃុំទាំង ៤ របស់ស្រុកកោះកុង ដែលដែលជាប់នឹងមាត់សមុទ្រ ហើយឃុំនេះត្រូវបានជ្រើសរើសជាឃុំគោលដៅសំរាប់ការអនុវត្តន៍រៀបចំផែនការប្រើប្រាស់ដីធ្លី ។ ដោយសារមានការព្រួយបារម្ភអំពីការអភិវឌ្ឍន៍ខុសទិសដៅមិនមានចីរភាព និង អាចបណ្តាលឱ្យមានការវិនាសដល់ធនធានធម្មជាតិ បរិស្ថានកាន់តែខ្លាំង និង បង្កឱ្យមានផលប៉ះពាល់ដល់កំរិតជីវភាពរស់នៅ និង ភាពសុខដុមរមនារបស់ប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រសនេះទាំងមូល ។

គោលបំណងចំបងនៃផែនការប្រើប្រាស់ដីធ្លីនៅឃុំជ្រោយប្រសនេះគឺ ដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ-គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ប្រកបដោយនិរន្តរភាព និង សមធម៌រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជួយធ្វើឱ្យសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីធ្លីក្នុងមូលដ្ឋានឃុំស្របតាមស្ថានភាពដីជាក់ស្តែង និង សក្តានុពលធម្មជាតិនៃដី ឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំជួយការពារធនធានដី និង ធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និង មិនឱ្យប្រើប្រាស់ខុសទិសដៅ រួមចំណែកក្នុងការកំណត់ និង គ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំឱ្យបានល្អស្វែងរកការគាំទ្របច្ចេកទេសបន្ថែមពីស្ថាប័នអង្គភាពនានា និង ពីផ្នែកឯកជនផងដែរ និង ជួយដល់ក្រុមប្រឹក្សាឃុំក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ នៅថ្នាក់ក្រោមជាតិក្នុងការរួមចំណែកដល់ការរៀបចំផែនការគ្រប់គ្រង និង ប្រើប្រាស់ធនធានដី និង ធនធានធម្មជាតិនៅក្នុងឃុំការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូលទាំងដីរដ្ឋ ទាំងដីឯកជន ។

ដូច្នេះក្រោយពីមានផែនការប្រើប្រាស់ដីធ្លីនេះ អាជ្ញាធរគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិពិសេសអាជ្ញាធរដែនដី នឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីធ្លីរបស់គាត់ទៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និង អនុម័តនៅថ្នាក់ខេត្ត ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមធ្វើការសំរេច ។

# ជំពូក១

# ព័ត៌មាន និងទិន្នន័យសម្រាប់គំរោងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

ឃុំជ្រោយប្រស់ស្ថិតនៅក្នុងស្រុកកោះកុងមានផ្ទៃដីសរុបប្រមាណ ៤៣,៦០១.៥ ហិកតា ស្ថិតនៅប៉ែកខាងត្បូងឆៀងខាងលិចទីរួមស្រុក ទីតាំងសាលាឃុំស្ថិតនៅលើទីទួលចំងាយពីមាត់សមុទ្រប្រមាណ ២០០ ម៉ែត្រ ។ ទីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋភាគច្រើននៅតាមមាត់សមុទ្រ ។

ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៧ ប្រជាពលរដ្ឋពុំបានប្រកបមុខរបរធ្វើស្រែចំការទេ ដោយយកមុខរបរនេសាទជាចំបង ។

ពីឆ្នាំ ១៩៨៧ មកដល់បច្ចុប្បន្នប្រជាពលរដ្ឋក្នុងឃុំងាកមកធ្វើស្រែមួយចំនួន លើផ្ទៃដី ៣៣៣,៧៣ ហិកតា ។ ប្រជាពលរដ្ឋក្នុងឃុំមានជីវភាពជាមធ្យម ដោយគាត់មានមុខរបរពីរគឺមុខរបរ នេសាទ និង ធ្វើស្រែចំការ ។

ការចិញ្ចឹមគោក្របីសំរាប់ជាឧបករណ៍កសិកម្ម ជ្រូក,មាន់,ទា ជាលក្ខណ:គ្រួសារបន្ទាប់បន្សំប៉ុណ្ណោះ ពុំមានភាពជាសហគមន៍នោះឡើយ នៅក្នុងឃុំមានតែសហគមន៍នេសាទមួយប៉ុណ្ណោះ ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កោះកុង | |
| ស្រុក/ក្រុង | កោះកុង | |
| ឃុំ/សង្កាត់ | ឈ្មោះ: ជ្រោយប្រស់ | លេខកូដ: ០៩០៣០១ |
| ចំនួនភូមិ | ២ ភូមិ ក្នុងនោះមាន :ភូមិជ្រោយប្រស់ និង ភូមិថ្មី | |

ឃុំជ្រោយប្រស់មានទីតាំងស្ថិតនៅចំងាយ ២២.០៧ គ.ម ពីផ្លូវជាតិលេខ ៤៨ ជាប់ឆ្នេរសមុទ្រគិតតាមផ្លូវគោក។ ហើយបើគិតតាមផ្លូវទឹកទៅកាន់ទីរួមខេត្តកោះកុងប្រវែង ៥០ គ .ម ដោយធ្វើដំណើរទៅតាមទូក ឬ អូប៊័រ ពុំទាន់មាន ផ្លូវគមនាគមន៍នៅឡើយទេ ។

ឃុំជ្រោយប្រស់មានផ្ទៃដីចំនួន ៤៣,៦០១.៥ ហិកតាចែកចេញជា ២ ភូមិ ក្នុងភូមិទាំង ២ ស្ថិតនៅជាប់តំបន់ឆ្នេរសមុទ្រហើយមានព្រំប្រទល់ខាងកើតទល់នឹងឃុំក្រពាំងរូងខាងជើងទល់នឹងឃុំកោះកាពិខាងលិចទល់នឹងសមុទ្រ និង ខាងត្បូងទល់នឹងឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ។

## ផែនទីបង្ហាញទីតាំង ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង




### ១.១.២ ប្រជាសាស្ត្រ

ឃុំជ្រោយប្រស់មានប្រជាជនសរុបចំនួន ៣៦៤ គ្រួសារ ប្រជាជនចំនួន ១,៩៧៦ នាក់ ក្នុងនោះស្ត្រី ៨០៦ នាក់ មានដង់ស៊ីតេ ៤ នាក់ក្នុង១គីឡូម៉ែត្រក្រឡា ។ របាយប្រជាពលរដ្ឋរស់នៅផ្តុំតាមមាត់ឆ្នេរនៅភូមិទាំង ២ ហើយសង់ផ្ទះនៅលើទីទួល និង មាត់សមុទ្រប្រជាពលរដ្ឋទាំងអស់កាន់សាសនាព្រះពុទ្ធ ។

<u>តារាងស្ថិតិប្រជាជនឃុំជ្រោយប្រស់ ឆ្នាំ២០០៨ តាមក្រុមអាយុ</u>

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ៩៣ | ៩៨ | ១៩១ | |
| អាយុ ០៥ឆ្នាំ | ២៣ | ២៤ | ៤៧ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ១២២ | ១៣៥ | ២៥៧ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៧២ | ៦៥ | ១៣៧ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៦៨ | ៦៨ | ១៣៦ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ១១៣ | ១១៧ | ២៣០ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ២៩៨ | ២៦៧ | ៥៦៥ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ១៧ | ១៦ | ៣៣ | អាយុចូលនិវត្តន៍ |

| | | | | |
|---|---|---|---|---|
| ប្រជាជនសរុប | **៨០៦** | **៧៩០** | **១៥៩៦** | |
| ចំនួនគ្រួសារសរុប | ៣៦៤ | | | |

ប្រភព: តារាងទិន្នន័យភូមិ ឆ្នាំ ២០០៨

### ១.១.៣ ភាពគ្មានដីធ្លី

យោងតាមការប្រជុំជាមួយក្រុមប្រឹក្សាឃុំឃើញថា គ្រួសារគ្មានដីលំនៅដ្ឋានមាន ១៥០ គ្រួសារ គ្រួសារទាំងនេះសព្វថ្ងៃតាំងទីលំនៅ នៅមាត់ឆ្នេរ និង នៅលើសមុទ្រ មានមុខរបរនេសាទងាយស្រួលចតទូក ។

**តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់**

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានលំនៅដ្ឋាន | ១៥០ | ៤១.២០% | |

ប្រភព: ឯកសារព័តិមាន ស្តីពីស្ថានភាពឃុំជ្រោយប្រស់



### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រស់ប្រមាណ ៨០ គ្រួសារស្មើ ២១.៩៨% មានមុខរបរធ្វើស្រែវស្សាដោយពឹងផ្អែកទៅលើទឹកភ្លៀង ហើយក៏សំបូរខាងនេសាទផងដែរ ក្នុងនោះមានប្រមាណ ២០១ គ្រួសារ ស្មើនឹង ៥៥.២២ % និងមានមុខរបរនេសាទទឹកប្រៃ ។ ដោយឡែកគ្រួសារមួយចំនួនក៏មានប្រកបរបរដាំដំណាំរយៈពេលវែង និង រយៈពេលខ្លី តែការដាំដំណាំនេះមិនសូវទទួលបានផលល្អប៉ុន្មានទេ រីឯមុខរបរផ្សេងទៀតប្រជាជនឃុំជ្រោយប្រស់បានធ្វើការពង្រីក

នូវមុខរបរបន្ថែមដូចជាប្រមូលទិញក្តាម បង្គា ត្រីគ្រប់ប្រភេទយកទៅលក់នៅខេត្ត និង ទុកលក់ក្នុងឃុំ ។ ជាមួយគ្នានេះដែរនៅមានគ្រួសារខ្លះទៀតចិញ្ចឹមគោក្របីជ្រូកមាន់ទា ។ល។

**តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំជ្រោយប្រស់**

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | មុខរបរកសិកម្ម | | | |
| | ធ្វើស្រែជាចំបង | ៨០ | ២១.៩៨% | ស្រូវសន្ទូង និងស្រូវចំការ |
| | ដាំដំណាំរយៈពេលវែងជាចំបង | ១៩ | ៥.២២% | ស្វាយ ដូងខ្ទុរ មៀន |
| | ដាំដំណាំរយៈពេលខ្លីជាចំបង | ១៧ | ៤.៦៧% | ពោត សណ្តែកដី ឪឡឹក |
| | ដាំដំណាំបន្លែជាចំបង | ១៥ | ៤.១២% | ត្រកួន ស្ពៃ ត្រសក់ ត្រប់ |
| ២ | មុខរបរនេសាទជាចំបង | ២០១ | ៥៥.២២% | លបក្តាម មងក្តាម ត្រី |
| ៣ | មុខរបរចិញ្ចឹមសត្វជាចំបង | ៣ | ០.៨២% | គោ,ក្របី,ជ្រូក,មាន់,ទា |

ប្រភព: ឯកសារព័ត៌មាន ស្តីពីស្ថានភាពឃុំជ្រោយប្រស់ ឆ្នាំ ២០០៨

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

- ឃុំជ្រោយប្រស់មានករិតសិក្សារហូតដល់ថ្នាក់អនុវិទ្យាល័យ មានសិស្សមត្តេយ្យត្រូវចូលរៀនមានចំនួន ៤៧ នាក់ពុំមានសាលាឡើយ ។ ចំពោះសាលាបឋមសិក្សាឃុំជ្រោយប្រស់មានចំនួន ០១ ខ្នង ស្មើ ៦ បន្ទប់ និង ថ្នាក់រៀនចំនួន ០៨ ថ្នាក់តែប៉ុណ្ណោះ និង មានគ្រូបង្រៀន ៥ នាក់ដែលមានសិស្សចំនួន ២៣៣ នាក់ ។
- ចំពោះអនុវិទ្យាល័យនៅឃុំជ្រោយប្រស់មានចំនួន ០១ ខ្នងស្មើនឹង ៥ បន្ទប់និង ថ្នាក់រៀនចំនួន ៣ ថ្នាក់តែប៉ុណ្ណោះ និងមានគ្រូបង្រៀនចំនួន ៥ នាក់ ដែលមានសិស្សចំនួន ១២១ នាក់ស្មើនឹង ៨៨.៣២ % ក្នុងចំណោមក្មេងអាយុពី ១២-១៤ ឆ្នាំ ចំនួន ១៣៧ នាក់នៅក្នុងឃុំ ។

-បើតាមការពិនិត្យជាក់ស្តែងឃើញថានៅខ្វះគ្រូបង្រៀនបន្ថែមទៀត ។

តារាងស្ថិតិសាលា និង ចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយ្យ | ០ | ០ | ០ | ៤៧ | ០ | ០ | ១០០% |
| ថ្នាក់បឋមសិក្សា | ១ | ៦ | ៨ | ២៥៧ | ២៣៣ | ១២៤ | ៩% |
| ថ្នាក់អនុវិទ្យាល័យ | ១ | ៥ | ៣ | ១៣៧ | ១២១ | ៥៩ | ១២% |
| ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | ១៣៦ | ១១៥ | ០ | ១៥% |

ប្រភព: ឯកសារព័ត៌មាន ស្តីពីស្ថានភាពឃុំជ្រោយប្រស់ ឆ្នាំ ២០០៨



### ១.១.៦ ស្ថានភាពសុខាភិបាល

#### ១.១.៦.១ ផ្នែកសុខាភិបាល

បច្ចុប្បន្នសេវាសុខាភិបាលនៅឃុំជ្រោយប្រស់ មិនទាន់មាននៅឡើយទេ សព្វថ្ងៃនេះពេលប្រជាជនមានជំងឺធ្ងន់ ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង ដែលដឹកជញ្ជូនតាមផ្លូវទឹកហើយមានចំងាយប្រមាណ ៥០ គ.ម ។ ប៉ុន្តែនៅក្នុងឃុំមានគ្រូពេទ្យឆ្មបស្ម័គ្រចិត្តបំរើការនៅទីនោះចំនួន ០៤ នាក់ដែលឧបត្ថម្ភដោយអង្គការឃែរ ។

តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០ | ០ | ០៤ | ០ | ០ |
| ២ | ប៉ុស្តិ៍សុខភាពភូមិ | ០ | ០ | ០ | ០ | ០ |

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ប្រភពនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងឃុំជ្រោយប្រស់ នៅពុំទាន់បំពេញសេចក្ដីត្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋនៅឡើយទេគឺពឹងផ្អែកលើទឹកភ្លៀងនៅរដូវវស្សា និង អណ្ដូងចំនួន ១១ អណ្ដូងដោយមានអណ្ដូងលូចំនួនតែ ៣ ប៉ុណ្ណោះដែលអាចប្រើបាននៅរដូវប្រាំង ។ ក្នុងនេះដែរ ឃុំក៏មានប្រព័ន្ធចែកចាយទឹកឯកជន ការចែកចាយទឹកនេះបានទឹកមកពីស្រះហើយប្រើមិនគ្រប់គ្រាន់ឡើយ ជាមូលហេតុធ្វើឱ្យប្រជាពលរដ្ឋទៅយកទឹកពីភ្នំកោះកុងក្រៅ ឬកន្លែងឆ្ងាយ ។

ចំពោះអណ្ដូងលូបានខូចខាតស្ទើរតែមិនអាចជួសជុលបាន តែតំរូវការឱ្យធ្វើការជួសជុល និង ស្ដារឡើងវិញ ។

**<u>តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំជ្រោយប្រស់</u>**

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្ដូងស្នប់ | 0 | 0 | 0 | 0 |
| ២ | អណ្ដូងលូ | ១១ | ៧ | ៤ | ខូចតែត្រូវជួសជុលឡើងវិញ |
| ៣ | អណ្ដូងមិនដាក់លូ | 0 | 0 | 0 | |
| ៤ | ស្រះទឹក | ១ | ១ | 0 | ប្រើនៅរដូវប្រាំងមិនគ្រប់គ្រាន់ |

<u>ប្រភព</u>: ឯកសារព័ត៌មាន ស្ដីពីស្ថានភាពឃុំជ្រោយប្រស់ឆ្នាំ ២០០៨



## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

- ឃុំជ្រោយប្រស់ស្ថិតនៅជាប់ឆ្នេរសមុទ្រ ឆៀងខាងលិចសាលាស្រុកកោះកុង ដែលមានចំងាយ ២២.០៧ គ.ម ហើយបើគិតពីផ្លូវទឹកមកកាន់ទីរួមខេត្តកោះកុង ប្រមាណជា ៥០ គ.ម ឃុំជ្រោយប្រស់ស្ថិតនៅក្នុងតំបន់ឧទ្យានជាតិបូទុមសាគរហើយមានព្រំប្រទល់ ខាងជើងទល់នឹងឃុំកោះកាពិ ខាងលិចទល់នឹងសមុទ្រខាងកើតទល់នឹងឃុំត្រពាំងរូង និង ខាងត្បូងទល់នឹងឃុំព្រែកខ្សាច់ ស្រុកគីរីសាគរ ។
- ឃុំជ្រោយប្រស់សំបូរទៅដោយដីមានជីវជាតិល្អ ហើយមានព្រៃលិចទឹកប្រមាណ ៣០ %ក្រៅពីនេះជាទីដីទួលផងដែរ ។

ឃុំជ្រោយប្រស់ផ្នែកខាងជើង ខាងកើត និង ផ្នែកខាងត្បូង មានរយៈកំពស់ពី ២១៦ -៤០២ ម ហើយផ្នែកខាងលិចមានរយៈកំពស់ ០-៨ ម ។

ផែនទីរយៈកំពស់ ក្នុងឃុំជ្រោយប្រស់




*រូប២ : ផែនទីរយៈកំពស់*

### ១.២.២ អាកាសធាតុ

នៅក្នុងខេត្តកោះកុងជាខេត្តមួយស្ថិតនៅក្នុងតំបន់ជួរភ្នំក្រវាញ និង ជាប់សមុទ្រទីតាំងនេះហើយដែលធ្វើឱ្យខេត្តកោះកុងសំបូរទឹកភ្លៀងជាក់ស្តែងដូចជានៅឆ្នាំ :

-២០០៣ : ភ្លៀងធ្លាក់ចាប់ផ្តើមពីខែកុម្ភៈរហូតដល់ខែតុលាតែភ្លៀងធ្លាក់ខ្លាំងនៅខែកក្កដា ដែលមានកំពស់ទឹកភ្លៀងរហូតដល់ ៨២៩.៨ មម កំពង់ទឹកភ្លៀងប្រចាំឆ្នាំ ២០០៣ មាន ២,៩៥២.៨ មម ។

-២០០៤ : ភ្លៀងធ្លាក់ចាប់ពីខែ កុម្ភៈរហូតដល់ខែ វិច្ឆិកា តែភ្លៀងធ្លាក់ខ្លាំងនៅខែ កក្កដា ដែលមានកំពស់ទឹកភ្លៀង ៩៥៣.៧ មម និង កំពស់ទឹកភ្លៀងប្រចាំឆ្នាំមាន ៣,៩៤៨.១ មម ។

-២០០៥ : ភ្លៀងធ្លាក់ចាប់ផ្តើមពីខែ មករា រហូតដលខែតុលា តែភ្លៀងធ្លាក់ខ្លាំងនៅខែ កក្កដា កំពស់ទឹកភ្លៀងមាន ១,០៤៣.0 មម កំពស់ទឹកភ្លៀងប្រចាំឆ្នាំមាន ៣,៥៤២.៨ មម ។

-២០០៦ : ភ្លៀងធ្លាក់ចាប់ផ្តើមពីខែ មករា រហូតដលខែ ធ្នូ តែភ្លៀងធ្លាក់ខ្លាំងនៅខែ កក្កដា កំពស់ទឹកភ្លៀងមាន ១,៤៣៩.៥ មម កំពស់ទឹកភ្លៀងប្រចាំឆ្នាំមាន ៤,៨៦៧.៩ មម ។

ដោយឡែកក្នុងឃុំជ្រោយប្រស់ ស្រុកកោះកុង នៅក្នុងឆ្នាំ ២០០៧-២០០៨ នេះមានកំពស់ទឹកភ្លៀងប្រចាំឆ្នាំ ២០០៧ មាន ៣,០១៧.0 មម និង កំពស់ទឹកភ្លៀងប្រចាំឆ្នាំ ២០០៨ មាន ៣,៨៣៤.0 មម ។

រយៈពេលនៃរដូវប្រាំងៈ ៥ ខែ គឺចាប់ពីខែ ធ្នូ ដល់ខែ មេសា ចំពោះការប្រែប្រួលមានភាពលំអៀងតិចតួចប៉ុណ្ណោះ ។

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

ឃុំជ្រោយប្រស់ជាឃុំមួយដែលស្ថិតនៅតំបន់ឆ្នេរ ឆ្ងាយពីទីរួមស្រុកពុំមានផ្លូវគោកធ្វើដំណើរទាក់ទង ទៅបណ្តាឃុំផ្សេងៗទៀតឡើយគឺ ធ្វើដំណើរបានតាមផ្លូវទឹកប៉ុណ្ណោះតាមទូក ឬ អូប័រ ។

ការធ្វើដំណើរនៅក្នុងភូមិទាំង ២ មានផ្លូវបេតុងពីរខ្សែ និង ផ្លូវលំដីសពីរខ្សែនៅក្នុងនោះមានផ្លូវបេតុងចេញពីភូមិជ្រោយប្រស់ទៅភូមិថ្មីមានប្រវែង ២៩០ ម៉ែត្រ ផ្លូវបេតុង ០១ ខ្សែទៀតសំរាប់ធ្វើដំណើរទៅវត្ត ឧទ័យព្យារាម ហៅវត្តជ្រោយប្រស់មានប្រវែង ១០០ ម៉ែត្រ ហើយផ្លូវនេះពុំទាន់បានតភ្ជាប់ទៅផ្លូវបេតុងពីភូមិជ្រោយប្រស់ទៅភូមិថ្មីនៅឡើយ ។

ដោយឡែកផ្លូវផែបេតុងមួយខ្សែនៅក្នុងភូមិជ្រោយប្រស់ប្រវែង ៩0 ម គឺសំរាប់បំរើឱ្យការធ្វើដំណើរពីដីគោកទៅសមុទ្រក្នុងការលើកដាក់ទំនិញរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ ។ រីឯបេតុងមួយខ្សែទៀតដែលនៅភូមិថ្មីមានប្រវែង ២00 ម ពីដីគោកទៅសមុទ្រសំរាប់បំរើឱ្យការធ្វើដំណើរចុះឡើង និង លើកដាក់ទំនិញផ្សេងៗទូទាំងឃុំ ។

ផ្លូវលំដែលមាននៅក្នុងឃុំជ្រោយប្រស់មានប្រវែង ១,២៣៩.១១ ម និង ទទឹងប្រវែង ៦ម សំរាប់តភ្ជាប់ពីទីប្រជុំជនជ្រោយប្រស់(ពីផ្លូវបេតុងទៅភូមិថ្មី) ទៅកាន់ចំការរបស់ប្រជាពលរដ្ឋនៅក្នុងភូមិជ្រោយប្រស់ ចំណែកផ្លូវលំ

មួយខ្សែទៀតដែលចេញពីភូមិជ្រោយប្រស់ទៅកាន់វាលស្រែខាងក្រោយភូមិជ្រោយប្រស់ ដែលអាចឱ្យប្រជាពលរដ្ឋបររទេះដឹក ផលិតផលស្រូវបាន ។

| កូដ | ប្រភេទផ្លូវ | ស្ថានភាព/ប្រវែងផ្លូវ | | សំគាល់ |
|---|---|---|---|---|
| | | ប្រវែងសរុប | ប្រវែងខូចខាត | |
| ១ | ផ្លូវបេតុង | ៣៩០ ម | 0 | ទើបសង់ថ្មី |
| ២ | ផែបេតុង | ២៩០ ម | 0 | ទើបសង់ថ្មី |
| ៣ | ផ្លូវលំថ្មើរជើង | ១,២៣៩.១១ ម | | |





## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំជ្រោយប្រស់អាចចែកចេញជា ៧ ចំណាត់ថ្នាក់សាមញ្ញរួមមានៈ ដីលំនៅដ្ឋាន (ផ្ទះនិង ដំណាំរួមផ្សំ) ដីកសិកម្ម (ស្រែវស្សា និង ចំការដំណាំ) ដីព្រៃគំរបព្រៃ(ព្រៃស្រោង) ដីព្រៃកោងកាង (ក្រាស់ ស្តើង)ព្រៃគុម្ពោត និង ដីស្មៅ (ព្រៃពួច-ស្បូវ ) ។ ផ្ទៃទឹក និង ខ្សែទឹក (បឹងព្រែកឆ្នេរ)ដីខ្សាច់ និង ថ្ម (ខ្សាច់ ស ថ្មដា) ។

**តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត**

| កូដ | ប្រភេទនៃការប្រើប្រាស់ដី (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) | ក្រឡាផ្ទៃ (ហិកតា) |
|---|---|---|---|
| | ដីលំនៅដ្ឋាន-ភូមិ | ផ្ទះទីសំណាប ឈើហូបផ្លែ | ២៩.៣២ |
| | ដីស្រែវស្សា | ស្រែស្រូវវស្សាបាន ១ រដូវ | ៣៣៣.៧៣ |
| | ដីចំការដំណាំ | ពោត ដំឡូងមី និង អំពៅ | ៧.២៥ |
| | ចំការឈើហូបផ្លែ | ធុរេន សាវម៉ាវ មង្ឃុត កំពីងរាជ ខ្នុរ ដូង ដំណាំរយៈពេលខ្លី ចេក ម្នាស់ | ២០០ |
| | ដីកសិកម្មពនេចរ | ដាំស្រូវចំការ(បច្ចុប្បន្នពុំមានឡើយ) | ៣៩៦.០៥ |
| | ដីព្រៃលាយចំការ | ចំការចាស់បូរាណ និងព្រៃ | ១,៣៩៩.៦៨ |
| | ដីព្រៃលាយដីកសិកម្ម | ព្រៃស្នាច់ និង ដីស្រែចាស់ | ១០២.៤៨ |
| | ដីព្រៃ /គំរបព្រៃ | | |
| | ដីព្រៃស្រោង (សើម) | គគីរខ្សាច់ គ្រញូង ចំបក់ | ៣២,៦៩២.២៤ |
| | ព្រៃដុះឡើងវិញ | ឈើគ្រប់ប្រភេទ | ១៤៦៥.៨៤ |
| | ដីព្រៃលិចទឹក | ស្នាច់ កាញ្ជីប | ៥៣០.៤១ |
| | ព្រៃកាប់ឆ្ការ | កាប់ព្រៃអនាធិបតេយ្យ | ៦៥.៧៥ |
| | ព្រៃកោងកាងក្រាស់ | | ២,២៩៣.៤០ |
| | ព្រៃកោងកាងស្តើង | | ៩២.២៨ |
| | វាលស្មៅ | សំបូរស្បូវ | ៧៤៥.២៨ |
| | ចំការបោះបង់ចោលដុះស្មៅ | ដីចំការចាស់ និង ស្បូវ | ៧៦.០០ |
| | វាលស្មៅលិចទឹក | | ២៩៧.៨៧ |
| | ព្រៃគុម្ពោត | ព្រៃពួច | ៥៦៧.៨៩ |
| | ព្រៃគុម្ពោតលាយដើមឈើធំ មួយៗ | | ៩៤.៩៥ |

| | | | |
|---|---|---|---|
| | បឹង | ក្រោយភូមិសំបូរត្រី | ៥៥.៨៨ |
| | សមុទ្រ | | ១,៣៦៤.១៣ |
| | ដីខ្សាច់ | ខ្សាច់ស | ១៣.៧៥ |
| ២៤ | ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់ | | ៦.៧២ |

ប្រភព: ទិន្នន័យព័ត៌មានភូមិសាស្ត្រ បានធ្វើបច្ចុប្បន្នភាពជាមួយក្រុមប្រឹក្សាឃុំ

## ១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី

ស្ថានភាពនៃការកាន់កាប់ និងគ្រប់គ្រងដីនៅក្នុងឃុំជ្រោយប្រសព្វក្រៅពីដីលំនៅដ្ឋាន ដីស្រែចំការដែលជាកម្មសិទ្ធិរបស់ឯកជន គឺសុទ្ធសឹងតែជាដីសាធារណៈរបស់រដ្ឋ (ឧទ្យានជាតិបូទុមសាគរ) ដែនជំរកសត្វព្រៃពាមក្រសោប និង ដីក្រុមហ៊ុន គ្រីនរិច ។

នៅក្នុងដំណាក់កាលបច្ចុប្បន្នស្ថានភាពកាន់កាប់រំាតដីឧទ្យានជាតិ និង ដែនជំរកសត្វព្រៃពាមក្រសោបកើតឱ្យមានជំលោះបញ្ហាដីធ្លី។

តារាងសង្ខេបស្ថានភាពកាប់កាប់និងគ្រប់គ្រងដី

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | តំបន់ឧទ្យានជាតិ | ២៧,៤៣៧.៣៣ | |
| ២ | ដែនជំរកសត្វព្រៃពាមក្រសោប | ៤២៤.៩៧ | |
| ៣ | ក្រុមហ៊ុនហ្គ្រីនរិច | ១៣,៣៤២.៨៤ | |
| ៤ | ដីឯកជន | | |
| ៥ | ដីផ្សេងៗ | | |

## ១.៣.៣ ផលិតកម្មកសិកម្ម

ប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រសព្វប្រមាណ ២១,៩៨% មានមុខរបរធ្វើស្រែវស្សាដោយពឹងផ្អែកលើទឹកភ្លៀងក្នុងការប្រើប្រាស់ទឹកដើម្បីបំរើអោយវិស័យកសិកម្ម ឃើញថាឃុំជ្រោយប្រសព្វនៅមានការខ្វះខាតនូវប្រព័ន្ធស្រោចស្រពសំរាប់បង្កបង្កើនផល និង ស្រោចស្រពនូវផលដំណាំផ្សេងៗផងដែរ ក្នុងនេះសំណង់សំរាប់ផ្គត់ផ្គង់ទឹកក៏ពុំទាន់មាន។

ឆ្នាំ ២០០៨ ដីស្រែចំនួន ៣៣៣,៧៣ ហិកតា ធ្វើបានតែចំនួន ២៥៧ ហិកតា ប៉ុណ្ណោះហើយទិន្នផលទៀតសោតទទួលបាន ១,៥ តោនក្នុង ១ ហិកតា ស្មើនឹង ៣៨៥,៥ តោន នៅក្នុងឆ្នាំ ២០០៨ និង ស្រូវចំការ មានផ្ទៃសរុប២៩ ហិកតា ធ្វើបានទាំងអស់ ០១ហិកតា ស្មើនិង ០១តោន សរុបស្មើនិង ២៩តោន

តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី ( ហត) | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប ( ហត) | ដាំបាន ( ហត) | ផលសរុប ( តោន) | ទិន្នផល ( ត/ហត) |
| ១ | ដំណាំស្រូវវស្សា | ៣៣៣,៧៣ | ២៩៧ | ៣៨៥.៥ | ១.៥ |
| ២ | ស្រូវចំការ | ២៩ | ២៩ | ២៩ | ១.00 |

ប្រភព: ឯកសារព័តិមាន ស្តីពីស្ថានភាពឃុំជ្រោយប្រស់ ទិន្នផលស្រូវមធ្យម ០១ ឆ្នាំ ចុងក្រោយ

បច្ចុប្បន្នការងារកសិកម្មដូចដែលបានលើករួចមកហើយនោះ គឺមានការពឹងពាក់លើទឹកភ្លៀងទាំងស្រុងដែលធ្វើឱ្យការទទួលផលមិនបានទៀងទាត់ ហើយទទួលបានទិន្នផលទាប តែទន្ទឹមនោះសក្តានុពលស្រោចស្រពសំរាប់ឃុំជ្រោយប្រស់មានលក្ខណៈអំណោយផលច្រើនទៀត បើយើងធ្វើការស្តារបឹងចាស់ដែលមានពីមុនមក និង ប្រឡាយចាស់ដែលមានប្រវែង ៣,៨00 ម និង ទំនប់ប្រវែង ៣,២១០ ម ឃុំជ្រោយប្រស់មានផែនការស្តារទំនប់ប្រឡាយទាំងនេះដើម្បីយកទឹកមកស្រោចស្រពផ្ទៃដី ១២៥ ហិកតា ដែលមាននៅក្នុងឃុំ ។

តារាងក្រឡាផ្ទៃតាមផលិតភាពដី និង ការប្រើប្រាស់ និងផលិតផល

| ឃុំជ្រោយប្រស់ | | | |
|---|---|---|---|
| | **ដីមានផលិតភាពទាប** | | |
| ១ | ដីចំការបោះបង់ដុះស្មៅ | 161.54 ha | |
| ២ | ដីគ្មានរុក្ខជាតិដុះគ្របដណ្តប់ | 83.73 ha | |
| ៣ | ព្រៃកាប់ឆ្ការ | 17.11 ha | |
| ៤ | ចំការដំណាំ | 211.75 ha | |
| ៥ | ព្រៃលិចទឹក | 157.96 ha | |
| ៦ | វាលស្មៅលិចទឹក | 11.85 ha | |
| ៧ | ល្បាយដីព្រៃលាយដីកសិកម្ម | 8 ha | |
| ៨ | ល្បាយដីព្រៃលាយដីចំការ | 1,199.70 ha | |

| | | | |
|---|---|---|---|
| ៩ | វាលស្មៅ | 426.55 ha | |
| ១០ | បឹង | 70.79 ha | |
| ១១ | ដីព្រៃកោងកាង | 40.56 ha | |
| ១២ | ព្រៃស្រោង | 836.76 ha | |
| ១៣ | ចំការឈើហូបផ្លែ | 35.21 ha | |
| ១៤ | ព្រៃកោងកាងស្តើង | 1,675.85 ha | |
| ១៥ | ឆ្នេរខ្សាច់ (Sand Bank) | 17.48 ha | |
| ១៦ | សមុទ្រ | 223.64 ha | |
| ១៧ | ព្រៃដុះឡើងវិញ | 9.12 ha | |
| ១៨ | ព្រៃគុម្ពោត | 59.48 ha | |
| ១៩ | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | 7,286.27 ha | |
| ២០ | កសិកម្មពនេចរ | 2,320.22 ha | |
| ២១ | ដីលំនៅដ្ឋានភូមិ | 0.08 ha | |
| ២២ | ដីស្រែវស្សា | 936.53 ha | |
| | **ដីមានផលិតភាពមធ្យម** | | |
| ១ | ដីចំការបោះបង់ដុះស្មៅ | 68 ha | |
| ២ | ព្រៃលិចទឹក | 9 ha | |
| ៣ | វាលស្មៅ | 196 ha | |
| ៤ | ដីព្រៃកោងកាង | 100 ha | |

| | | | |
|---|---|---|---|
| ៥ | ព្រៃស្រោង | 941 ha | |
| ៦ | សមុទ្រ | 10 ha | |
| ៧ | ព្រៃដុះឡើងវិញ | 456 ha | |
| ៨ | ព្រៃគុម្ពោត | 68 ha | |
| ៩ | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | 10 ha | |
| ១០ | កសិកម្មពនេចរ | 298 ha | |

ប្រភព: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




រូបផែនទីផលិតភាពដី

### ១,៣,៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

ផ្ទៃដីព្រៃនៅឃុំជ្រោយប្រស់គឺសុទ្ធសឹងតែជាដីព្រៃក្នុងតំបន់ឧទ្យានជាតិបូទុមសាគរស្ទើរតែទាំងអស់ ក្រៅពីនេះមានព្រៃលិចទឹកមួយចំនួនទៀត ព្រៃលិចទឹកទាំងអស់នេះជាតំបន់អេកូឡូស៊ី និង ជាមុខងារសេដ្ឋកិច្ចយ៉ាងសំខាន់ ហើយក្រៅពីឈើសំរាប់សំណង់បន្ទាប់បន្សំ និង ជាឈើថាមពលព្រៃលិចទឹកជាកន្លែងដែលជាជំរកសំរាប់ត្រីពងកូន និង ជាក្រភពនៃចំណើដ៏សំបូរបែបសំរាប់មច្ឆាជាតិ ដោយឡែកវាលស្មៅដ៏ល្វឹងល្វើយនៅតំបន់ខាងលើនេះជាជំរក និង ជាកន្លែងសំរាប់រកចំណើរបស់ប្រភេទបក្សីទឹកច្រើនប្រភេទមានតំលៃនៅទីនោះទៀតផង ។ ប្រភេទព្រៃលិចទឹកមានដើមកោងកាង ក្រញ៉ូប ស្ទាច់ ផ្ទុង ដែលជាជំរកត្រី បង្គា ក្តាម អណ្តើក ពស់គ្រប់ប្រភេទ ត្រីរស់ ត្រីឆ្តុងស ក្របាម ។ ដែលអាចទាញយកផលនេសាទបានយ៉ាងច្រើនក្នុងមួយឆ្នាំៗ។



#### ១.៣.៤.២ ធនធានជលផល

ឃុំជ្រោយប្រស់ជាឃុំមួយដែលស្ថិតនៅជាប់នឹងសមុទ្រ ដូចនេះវាមានធនធានជលផលទឹកប្រៃច្រើន ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឃុំ មានមុខរបរធ្វើការនេសាទអាចរកប្រាក់កំរៃពីផលនេសាទបន្ថែមលើមុខរបរធ្វើស្រែចំការ ដើម្បីសំរាលជីវភាពគ្រួសារមួយកំរិតទៀត ជារៀងរាល់ឆ្នាំប្រជានេសាទនៅក្នុងឃុំអាចប្រកបអាជីវកម្មនេសាទដោយប្រើប្រាស់ឧបករណ៍សាមញ្ញដូចជា មង លប សន្ទូច...........ទោះបីជាការប្រើប្រាស់ឧបករណ៍សាមញ្ញយ៉ាងនេះក្តី បានធ្វើឱ្យប្រជានេសាទក្នុងតំបន់នេះមានជីវភាពល្អបង្គួរដែរ ។

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

នៅក្នុងឃុំជ្រោយប្រស់ការធ្វើស្រែវស្សាពុំសូវបានផលប៉ុន្មានឡើយ ។ តែផលដែលបានមកប្រជាពលរដ្ឋលក់ចេញបានតំលៃជាមធ្យម ១ គ.ក ៩២៥ រៀល តំលៃខ្ពស់បំផុតតំលៃ ១ គ.ក តំលៃ ១,១០០ រៀល និង តំលៃទាប បំផុត ១ គ.ក តំលៃ ៧៥០ រៀល ( គិតក្នុងឆ្នាំ ២០០៨ យោងស្ថិតិភូមិ ) ។

ក្រៅពីធ្វើស្រែ និង ចំការប្រជាពលរដ្ឋភាគច្រើនមានមុខរបរនេសាទជាចំបងដល់ទៅ ២០១ គ្រួសារឯណោះ ចំណែកឯផលនេសាទទឹកប្រៃដូចជាក្តាមថ្ម ក្តាមសេះ ត្រីតុកកែ ត្រីឆ្តុង មឹក ត្រីកាម៉ុង បង្គា ។ល។ រីឯតំលៃទីផ្សារមាន ដូចតទៅ :

| | | |
|---|---|---|
| +ក្តាមថ្ម | ១គ.ក តំលៃ | ១១,០០០ រៀល ( លក់ក្នុងឃុំជ្រោយប្រស់) |
| +ក្តាមសេះ | ១គ.ក តំលៃ | ៦,០០០ រៀល ( លក់ក្នុងឃុំជ្រោយប្រស់) |
| +ត្រីឆ្តុង | ១គ.ក តំលៃ | ៨,០០០ រៀល( លក់ក្នុងឃុំជ្រោយប្រស់) |
| +បង្គា | ១ គ.កតំលៃ | ១២,០០០ រៀល |
| +ត្រីកាម៉ុង | ១ គ.កតំលៃ | ១,៥០០ រៀល |

( តំលៃនៅក្នុងឃុំឆ្នាំ ២០០៨ នេះ)

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

ប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រស់ប្រមាណ ៨០ គ្រួសារធ្វើស្រែវស្សាលើផ្ទៃដី ២៩៧ ហិកតា ផលសរុបបាន ៣៨៥.៥ តោនក្នុង ១ ឆ្នាំ ទោះជាផលិតផលស្រូវធ្វើបានជារៀងរាល់ឆ្នាំ ក៏ដោយក៏នៅមិនទាន់បានបំពេញនូវតំរូវការគ្រប់គ្រាន់ឡើយ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋទិញអង្ករពីទីផ្សារផ្សេងៗ មកបំពេញតំរូវការប្រចាំថ្ងៃគឺ អង្ករ ១គ.ក ជាមធ្យមតំលៃ ២,៥០០ ៛ ទីផ្សារខេត្តកោះកុង ។

### ១.៤.៣ ឱកាស និង ឧបសគ្គ

ចំពោះធនធានជលផល គឺជាធនធានដែលមានសក្តានុពលយ៉ាងខ្ពស់ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋក្នុងឃុំជ្រោយប្រស់ ក៏ដូចជាសេដ្ឋកិច្ចជាតិ តែការប្រើប្រាស់ធនធានមានការប៉ះពាល់យ៉ាងខ្លាំង គឺធ្វើឱ្យធនធានទទួលរងនូវគ្រោះថ្នាក់ ដោយការកាប់ព្រៃលិចទឹកធ្វើជាស្រែចិញ្ចឹមក្តាម ឬ បង្កង ក្រៅពីនេះប្រើឧបករណ៍ទំនើបខុសច្បាប់ដូចជា ការប្រើលបក្រឡាតូច ដែលខុសពីការណែនាំ និង ធ្វើឱ្យទិន្នផលថយចុះ។

# ជំពូក២

# ការវិភាគពីតម្រូវការសំរាប់អនាគត ឧបស័គ្គ និង សក្តានុពល

## ២.១ តំបន់សើប

តំបន់ព្រៃលិចទឹក និង វាលស្មៅជាប់ដែសមុទ្រ ជាតំបន់ដីល្បាប់ថ្មីហើយសំបូរទៅដោយ ស្មៅប្រយុង ដុះយ៉ាងក្រាស់លាយដើមកោងកាង លាយក្រញ៉ូប ស្ទាច់ ជាតំបន់ជីវចំរុះ យ៉ាងពិសេស និង ជាដែនជំរកត្រីពងកូន ។ តំបន់នេះត្រូវតែថែរក្សាទុកជាព្រៃលិចទឹកដដែល ហើយមិនអាចពង្រីកជាដីកសិកម្មបានឡើយ ព្រៃលិចទឹកដុះលាយដើមស្ទាច់ហើយមានផលប្រយោជន៏យ៉ាងខ្លាំងសំរាប់ពពួកសត្វស្លាបរស់នៅ និង រកចំណីអាហាររបស់ពួកវាដូចជាសត្វជ្រើង សត្វមាន់ទឹក សត្វកុក ក្រសារ និង សត្វស្លាបជាច្រើនប្រភេទដែលរស់នៅទីនោះទៀតផង ។

តំបន់រក្សាទុកសំរាប់បំរើផលប្រយោជន៏សាធារណៈក្នុងគោលដៅការពារបរិស្ថាន និង ធនធានធម្មជាតិក្នុងឃុំជ្រោយប្រសម៉ានៈ

-ឧទ្យានបូទុមសាគរមានទំហំ ២៧,៤៣៧.៣៣ហិកតា

-ដែនជំរកសត្វព្រៃពាមក្រសោបមានទំហំ ៤២៤.៩៧ ហិកតា

## ២.២ ការប្រឈម/ឧបស័គ្គ

ក្នុងឃុំជ្រោយប្រសម៉ានបញ្ហាប្រឈមជាច្រើន តែបញ្ហាប្រឈមដែលមានការពាក់ព័ន្ធដល់ធនធានធម្មជាតិ ក៏ដូចជាការប្រើប្រាស់ដីមានដូចខាងក្រោម :

-ការកើនឡើងរបស់ប្រជាពលរដ្ឋ គឺជាការកើនឡើងនូវតំរូវការដែលជាកត្តាធ្វើឱ្យមានការប៉ះពាល់ដល់ការប្រើប្រាស់នៅធនធាន ។បច្ចុប្បន្នការកើនឡើងរបស់ប្រជាជនក៏ដូចជាការកើនឡើងនៃមុខរបរនេសាទ ដូច្នេះដើម្បីបំពេញបាននូវសេចក្តីត្រូវការរបស់ពួកគេគឺត្រូវបង្កើនការចាប់ត្រីធម្មជាតិទើបអាចឆ្លើយតបនឹងតំរូវការប្រើប្រាស់ ។ ប៉ុន្តែ ជាការពិតដែននេសាទមិនមានការកើនឡើងឡើយ ។ ដោយអនុលោមទៅតាមគោលនយោបាយក្នុងការកែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល និង ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដោយបង្កើនប្រាក់ចំណូលតាមរយៈការប្រើប្រាស់នូវដែននេសាទប្រកបដោយចិរភាព ។

-ឆ្លងតាមការប្រើប្រាស់ដីស្រែ ចំការ កន្លងមកដោយមិនគិតពីផលប៉ះពាល់ទៅលើដីឡើយ គឺអាស្រ័យដោយការប្រើប្រាស់ពុំបានគិតគូរពីលក្ខណៈបច្ចេកទេសកសិកម្មឡើយ ជាហេតុបណ្តាលឱ្យទទួលរងនូវគ្រោះថ្នាក់នៃការបាត់បង់ជីវជាតិដែលមូលហេតុនេះមានជាអាទិ៍ មកពីការបាត់បង់ព្រៃឈើ ការធ្វើកសិកម្មមិនមានបច្ចេកទេសគ្រប់គ្រាន់ ការដាំដំណាំដដែលៗលើផ្ទៃដីតែមួយ ការប្រើប្រាស់ជីគីមីមិនត្រឹមត្រូវដែលធ្វើឱ្យដីខ្សោះជីវជាតិ និង ខូចរចនាសម្ព័ន្ធដី ក៏ដូចជាសារធាតុជីវចំរុះក្នុងដី ។

-ទិន្នផលស្រូវទាបដោយមកពីកត្តាដីថយនូវជីវជាតិ និង មិនមានប្រព័ន្ធស្រោចស្រពដោយពឹងលើទឹកភ្លៀង ហើយការជ្រើសរើសពូជមិនបានត្រឹមត្រូវ រីឯជំងឺស្រូវក៏មិនអាចធានាបាន ។

-ការកាប់រុករានទន្រ្ទានដីផ្សេងៗនៅក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ ដែនជំរកសត្វព្រៃពាមក្រសោប ដោយសារសព្វថ្ងៃនេះ ការកំណត់ព្រំដីប្រជាពលរដ្ឋប្រើប្រាស់នៅមិនទាន់បានត្រឹមត្រូវនៅឡើយ ។ ជាហេតុធ្វើឱ្យការកាន់កាប់ទន្ទ្រានដីយកធ្វើជាកម្មសិទ្ធិ បច្ចុប្បន្នកំពុងមានសកម្មភាពគួរឱ្យកត់សំគាល់ ។

## ២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ និង គោលដៅជាយុទ្ធសាស្រ្តឃុំជ្រោយប្រស់

នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ និង គោលដៅជាយុទ្ធសាស្រ្តឃុំបានធ្វើការលើកឡើងនូវគម្រោងផែនការសំរាប់ពេលអនាគត ដែលក្នុងនោះត្រូវបានកំណត់នូវផែនការជាអាទិភាពដូចខាងក្រោម :

- ការសាងសង់ផ្លូវថ្នល់ក្នុងនោះរួមមានផ្លូវបេតុង ផ្លូវរទេះ ផ្លូវថ្មើរជើង និង ផ្លូវក្រាលគ្រួសក្រហម និង ធ្វើការរៀបចំសហគមន៍ថែទាំផ្លូវដើម្បីធានាដល់ការប្រើប្រាស់មានភាពយូរអង្វែង ។

- ដើម្បីធានានូវការ ប្រើប្រាស់ទឹក និង ដើម្បីជំរុញ ការលើកកំពស់ទិន្នផលស្រូវទៅអនាគត ឃុំមានគោលការណ៏ធ្វើទំនប់ និង ទ្វារទឹកទប់ទឹកប្រៃកុំឱ្យហូរចូលក្នុងស្រែ និង កសាងប្រឡាយមេ ប្រឡាយរង យើងអាចជំរុញដល់ការធ្វើស្រែ ហើយបានទិន្នផលខ្ពស់ ។

- បច្ចុប្បន្ននៅក្នុងឃុំជ្រោយប្រសទាំងមូលពុំទាន់ធានាបានក្នុងការប្រើប្រាស់ទឹកស្អាត និងការថែទាំសុខភាពអនាម័យនៅឡើយជាបណ្តើរៗការយល់ដឹងពីប្រជាពលរដ្ឋ បាននិងកំពង់ចាប់អារម្មណ៏ទៅលើការស្តារ ស្រះទឹក អណ្តូងទឹក។

-នៅក្នុងការគាំទ្រលើការសិក្សាអប់រំ ឃុំបានកំណត់ចេញជាគោលការណ៏ក្នុងការសាងសង់នូវអគារសិក្សាបន្ថែម សាលាបឋមសិក្សា ០១ អគារ ដែលស្ថិតក្នុងបរិវេណសាលាចាស់ ។

-ចំពោះវិស័យសុខភាពសាធារណៈ នៅក្នុងឃុំពុំទាន់មានប៉ុស្តិ៍សុខភាពនៅឡើយ ដូច្នេះពុំអាចបំរើសេវាកម្មជូនប្រជាពលរដ្ឋបានគ្រប់គ្រាន់ សព្វថ្ងៃពេលប្រជាជនមានជំងឺធ្ងន់ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង ដែលដឹកជញ្ជូនតាមផ្លូវទឹកដែលមានចំងាយប្រមាណ ៥០ គ.ម ។ ដូច្នេះជាគោលការណ៏ ឃុំបានលើកគម្រោងផែនការសាងសង់ប៉ុស្តិ៍សុខភាព ០១ ខ្នង ។

-នៅក្នុងការថែរក្សាធនធានធម្មជាតិ ឃុំបានធ្វើការចាប់អារម្មណ៏ទៅលើការដាំដើមឈើឡើងវិញ ដាំព្រៃលិចទឹកដូចជា កោងកាង ការកំណត់ព្រំឧទ្យានជាតិ ដែនជំរកសត្វព្រៃពាមក្រសោប និង ដីសំរាប់ប្រជាជនប្រើប្រាស់ បោះបង្គោលព្រំការពារ ស្មៅសមុទ្រ ។ ការអនុវត្តន៏បាននូវយុទ្ធសាស្រ្តនេះ វាអាចផ្តល់នូវផលប្រយោជន៏យ៉ាងច្រើនដល់ប្រជាជនក្នុងតំបន់ ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការដកយកផលពីធនធាន។

## ២.៤ តម្រូវការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រស់បើពិនិត្យទៅតាមបណ្តាឆ្នាំនីមួយៗ ឃើញថាមានការកើនឡើងបន្តិចបន្តួចឆ្នាំខ្លះថយចុះបើពិនិត្យទៅចំនួនគ្រួសារក៏កើនឡើងតិចតួចដែរ រីឯប្រជាពលរដ្ឋមានការថយចុះស្ទើរគ្រប់ឆ្នាំជាអាទិ៍ដូចជាក្នុងឆ្នាំ ២០០៥ ចំនួនប្រជាជនមានតែ ១,៥៨៨ នាក់ ឆ្នាំ ២០០៦ មានចំនួន ១,៥៧៦ នាក់ រីឯឆ្នាំ ២០០៧ មានចំនួន១,៤៥៥ នាក់ និងឆ្នាំ ២០០៨ មានចំនួន ១,៥៧៦ នាក់ ។កត្តាទាំងនេះតាមការសាកសួរព័ត៌មានគឺបណ្តាលមកពីការធ្វើចំណាកស្រុក ចេញទៅរកមុខរបរនៅខាងក្រៅស្រុក បើសិនពិនិត្យទៅលើកុមារក៏មានការកើនឡើងគួរឱ្យកត់សំគាល់ រហូតធ្វើឱ្យមានការកើនឡើងនូវកង្វះខាតទីកន្លែងសិក្សា ហើយក្នុងនោះចំពោះដីធ្លីនៅក្នុងឃុំក៏មានការខ្វះខាតដីក្នុងការពង្រីកវិស័យកសិកម្មដែរ ដូច្នេះពីមួយឆ្នាំទៅមួយឆ្នាំ ប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ហើយធ្វើឱ្យយើងមានការកត់សំគាល់លើសក្តានុពលមួយចំនួនដូចជា លទ្ធភាពនៃការពង្រីកការសិក្សា ការបង្កើតមុខរបរ ការពង្រីកដីស្រែបង្កើតនូវទិន្នផលកសិកម្ម ការរៀបចំប្រព័ន្ធស្រោចស្រព ការអភិវឌ្ឍន៏ធនធានធម្មជាតិ និងកំណត់ព្រៃសំរាប់ប្រើប្រាស់ធនធានឱ្យបានសមស្របអាចធានាបាននូវអត្រាកំណើន ។

| ចំនួនគ្រួសារ/ប្រជាជន | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | **៣៣៦** | **២៩៣** | **២៧៣** | **៣៦៤** | **-** | - |
| អត្រាកំណើនគ្រួសារ | | -១៣% | -៧% | ៣៣% | **៤.៥៧%** | ១៨ គ្រួសារ |
| ចំនួនប្រជាជនសរុប | **១៥៨៨** | **១៥៧៣** | **១៤៥៤** | **១៥៥៦** | **-** | - |
| អត្រាកំណើនប្រជាជន | | -១% | -៨% | ១០% | **០,៤២%** | ៧២ នាក់ |

យោងតាមតារាងទិន្នន័យភូមិពីឆ្នាំ ២០០២-២០០៧ ចំនួនប្រជាពលរដ្ឋ ក៏ដូចជាចំនួនគ្រួសារមានការថុចុះជាលំដាប់ ហើយការថយចុះនេះបណ្តាលមកពីមូលហេតុដូចខាងក្រោមៈ

-ចំណាកស្រុកទៅធ្វើកម្មករនៅប្រទេសថៃ

-ទៅធ្វើកម្មករសំណង់នៅភ្នំពេញ និង តាមបណ្តាខេត្តផ្សេងៗ

ចំណែកនៅឆ្នាំ២០០៨ ចំនួនប្រជាពលរដ្ឋបានកើនឡើងបន្តិចបន្តួច តែចំនួនគ្រួសារមានការកើនឡើងលឿនជាង គឺរហូតដល់ ៥% ។ បើគិតតាមការសាកសួរព័ត៌មានពីក្រុមប្រឹក្សាឃុំបានអោយដឹងថា កត្តានេះបណ្តាលមកពីគ្រួសារភាគច្រើនបានវិលត្រឡប់មកនេសាទវិញ តែមិនបាននាំមកចំនួនសមាជិកទាំងអស់នោះទេ ដោយទុកអោយសមាជិកផ្សេងៗទៀត ជួយរកប្រាក់ចំណូលបន្ថែមនៅតំបន់ផ្សេងៗទៀត។ អាស្រ័យហេតុនេះ ការគណនាកំណើនប្រជាជនអាចត្រូវបានគិត ដោយផ្អែកលើទំហំគ្រួសារមធ្យមក្នុងឆ្នាំគោល គឺឆ្នាំ២០០៨។ ដោយហេតុថា នៅឆ្នាំ ២០០៨ មានកើនឡើងចំនួន ៥គ្រួសារ ឬ ២០នាក់ (ទំហំគ្រួសារ ៤នាក់/គ្រួសារ)។ ឃុំជ្រោយប្រស់អំឡុងឆ្នាំ ២០០៥ ដល់

២០០៦ ឃើញថាមានការថយចុះ ១២,៨ % តែចាប់ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧ ឃើញថាភាគរយចំនួនគ្រួសារនៅដដែលមិនប្រែប្រួលទេ ដល់ឆ្នាំ ២០០៧ ដល់ ឆ្នាំ ២០០៨ អត្រានៃការប្រែប្រួលមានការកើនឡើង ២៤.៨ % ផ្អែកទិន្នន័យព័តិមាន នៃផែនការអភិវឌ្ឍន៍ឃុំឆ្នាំ ២០០៨-២០២២ របស់ឃុំជ្រោយប្រស់បានឱ្យដឹងថាប្រជាជនមានការថយចុះព្រោះដោយសារមូលហេតុដែលបានរៀបរាប់ខាងលើ ។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុក្រោម០៥ឆ្នាំ | ២២៥ | ១១៦ | ២៦៩ | ១៣៨ | ៣១២ | ១៦០ | |
| អាយុ ០៥ឆ្នាំ | ៥៥ | ២៨ | ៦៦ | ៣៤ | ៧៧ | ៣៩ | |
| អាយុពី ៦-១១ឆ្នាំ | ៣០៣ | ១៥៩ | ៣៦១ | ១៩០ | ៤១៩ | ២២០ | |
| អាយុពី ១២-១៤ឆ្នាំ | ១៦២ | ៧៧ | ១៩៣ | ៩១ | ២២៤ | ១០៦ | |
| អាយុពី ១៥-១៧ឆ្នាំ | ១៦១ | ៨០ | ១៩១ | ៩៦ | ២២២ | ១១១ | |
| អាយុពី ១៨-២៤ឆ្នាំ | ២៧២ | ១៣៨ | ៣២៣ | ១៦៥ | ៣៧៥ | ១៩១ | |
| អាយុពី ២៥-៦០ឆ្នាំ | ៦៦៧ | ៣១៥ | ៧៩៤ | ៣៧៥ | ៩២២ | ៤៣៦ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ៣៩ | ១៩ | ៤៦ | ២២ | ៥៤ | ២៦ | |
| **ចំនួនប្រជាជនសរុប** | **១៨៨៤** | **៩៣៣** | **២២៤៤** | **១១១១** | **២៦០៤** | **១២៨៩** | |
| **ចំនួនគ្រួសារសរុប** | **៤៣០** | | **៥១២** | | **៥៩៤** | | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំជ្រោយប្រស់ បើពិនិត្យទៅលើកំណើនក្នុងរយៈពេល៥ ឆ្នាំម្តងសំរាប់រយៈពេល១៥ឆ្នាំ ខាងមុខឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យមមានការកើនឡើង 0.៤២% ក្នុងនោះ ស្មើរនឹង -៧២ នាក់ ក្នុងមួយឆ្នាំនេះយោងតាមចំណោលប្រជាសាស្ត្រដល់ឆ្នាំ ២០២២ នោះប្រជាពលរដ្ឋមានការកើនឡើងគួរឱ្យកត់សម្គាល់ ឯចំនួនគ្រួសារតាមចំណោលប្រជាសាស្ត្រមានការកើនឡើងស្មើនឹង ៤.៥៧% ស្មើនឹង ១៥ គ្រួសារក្នុងមួយឆ្នាំ នោះបើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បាននៅមានក៏រិត ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៏ដែរ វាពាក់ពន្ធ័ទៅលើការអភិវឌ្ឍន៏ធនធានដែលមានក្នុងឃុំពិសេសបរិមាណដី ដែលអាចបង្កើននូវបរិមាណផលដើម្បីធានាស្បៀងក្នុងតំបន់ ។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាននៅឃុំជ្រោយប្រស់ មានទំហំតូចព្រោះលំនៅដ្ឋានសព្វថ្ងៃភាគច្រើនតាំងនៅតាមឆ្នេរសមុទ្រ និងលើសមុទ្រ ដែលជាទ្រព្យសាធារណៈរបស់រដ្ឋ ។ ចំណែកលំនៅដ្ឋានជាក់ស្តែងមានទំហំប្រមាណ ២៩.៣២ ហិកតា សំរាប់ប្រជាជន ២១៤ គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជាមធ្យមគឺ 0.១៤ ហិកតាដែលជា ទំហំមួយតូចសំរាប់ប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាលបែបនេះ ។ នៅពេលកំណត់តំរូវការដីលំនៅដ្ឋាន ពេលអនាគតឃុំកំណត់

យកតាមការបែងចែកដីសម្បទានសង្គមកិច្ចគឺដីលំនៅដ្ឋាន ១ គ្រួសារស្មើ ២៥០០ ម$^{២}$ ( យោងអនុក្រឹត្យលេខ :១៩ អ ន ក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០០៣ ) ។

ដូច្នេះតម្រូវការដីសំរាប់ឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារបច្ចុប្បន្នមិនមានដីលំនៅដ្ឋាន

១៥០ គ្រួ. x ២,៥០០ = ៣៧៥,០០០ ម$^{២}$ = ៣៧.៥០ ហត.

-កំណើនគ្រួសារឆ្នាំ ២០២២

២៣០ គ្រួ. x ២,៥០០ = ៥៧៥,០០០ ម$^{២}$ =៥៧.៥០ ហត.

សរុប = **៩៥ ហត.**

## ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ស្រែវស្សា និងចំការដំណាំរយៈពេលវែង និង ដីដាំបន្លែសំរាប់ឆ្នាំ ២០០៨ មានទំហំ ៥៤០.៩៩ ហិកតា សំរាប់ប្រជាជនសរុប ៣៦៤ គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ១,៤៨ ហិកតា ។ តែប្រជាជននៅក្នុងឃុំជ្រោយប្រស់នៅមានមុខរបរសំខាន់ មួយទៀតគឺរបរនេសាទទឹកប្រៃ ។ តែតាមស្ថិតិឃុំមានតែ ៣៥.៩៩ % តែប៉ុណ្ណោះដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម គឺមានប្រមាណ ៣១ គ្រួសារដែលមានដីជាមធ្យម ៤.១២ ហិកតា នេះជាទំហំធំមិនអាចយកទៅគណនារកតំរូវការដីកសិកម្មសំរាប់គ្រួសារនាពេលអនាគតបានឡើយ ។ ម្យ៉ាងទៀតយោងលើភូមិសាស្ត្រឃុំជ្រោយប្រស់សំបូរព្រៃភ្នំពុំអាចរកដីឱ្យបានធំទូលាយបានឡើយ ។ ដូច្នេះអាច ១ គ្រួសារបានជាមធ្យម ១.៥ ហិកតា

តំរូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

-កំណើនពីឆ្នាំ ២០២២

២៣០ គ្រួ. x ១,៥ = ៣៤៥ ហត.

ខាងលើនេះជាការវិភាគទៅតាមទំហំដី តែបើយើងវិភាគទៅតាមចំនួនប្រជាជន ផ្ទៃដីដាំដំណាំស្រូវគឺយើងឃើញថា ទិន្នផលស្រូវមាន ១,៥ តោន ក្នុង ១ ហិកតា ហើយប្រជាជនម្នាក់ៗត្រូវការ ២៣០ គ.ក ក្នុង ១ ឆ្នាំ តាមស្ថិតិឃុំផ្ទៃដីស្រែមាន ៣៣៣.៧៣ ហិកតា ទទួលបានផលស្រូវ ៥០០.៦០ តោនតំរូវការជាក់ស្តែង ៣៦៧.០៨ តោន លើសពីតំរូវការ ១៣៣.៥១ តោន ។ ឯកំនើនប្រជាជនរហូតដល់ឆ្នាំ ២០២២ គឺមាន ១,០០ នាក់ ត្រូវការស្រូវតែ ២៣១.៨៤ តោន តែប៉ុណ្ណោះ ។ ការពង្រីកដីកសិកម្មជាអាទិភាពអាចគួរពង្រីកប្រមាណ ១២៧.៥ ហិកតា សំរាប់ទល់នឹងឆ្នាំ ២០២២ ។

## ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ដោយនៅឃុំជ្រោយប្រស់ សំបូរទៅដោយព្រៃលិចទឹក និង វាលស្មៅ ដូច្នេះដីដែលបានកំណត់នៅក្នុងតំបន់រសើប និង ដីផ្សេងៗទៀតដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកឱ្យនៅជាដីព្រៃ

និងវាលស្មៅសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ពិសេសគឺ បណ្តាបឹងបួរធម្មជាតិដែលជាប្រភពដ៏ចំបង សំរាប់ធនធានជលផលផ្នែកទឹកសាប ។

### ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជនដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្ត អាស្រម សាលាឆទាន ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុងសំរាប់ពង្រីកទីប្រជុំជន។

តាមការប៉ាន់ស្មានប្រមាណជាសរុប ដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធគឺមានតំរូវការបន្ថែមចំនួន ៩៥ ហិកតា ចំពោះផ្លូវទំនប់តូចៗគឺមិនបានគិតជាផ្ទៃដីទេ តែបានគណនាប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក ។

តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 0 | | |
| សាលាបឋមសិក្សា | ១ | ២ | ១ |
| សាលាអនុវិទ្យាល័យ | ១ | ១ | 0 |
| សាលាវិទ្យាល័យ | 0 | | |
| មណ្ឌលសុខភាព | 0 | 0 | 0 |
| ប៉ុស្តិ៍សុខភាព | 0 | ១ | ១ |
| ស្រះទឹកស្អាត | ១ | ១ | 0 |
| អណ្តូងទឹកស្អាត | ១១ | ១១ | 0 |
| កន្លែងចាក់សំរាម | 0 | ១ | ១ |
| ទីតាំងផ្សារ | 0 | 0 | 0 |
| ប៉ុស្តិ៍នគរបាល | ១ | ១ | 0 |

#### ២.៤.៥.១ តម្រូវការដីសាលារៀន

នៅក្នុងឃុំជ្រោយប្រសព្វថ្ងៃ សាលាបឋមសិក្សា និង អនុវិទ្យាល័យ ស្ថិតនៅលើទីតាំងដីតែមួយ ដែលមានទំហំ ៩៥ ម គុណ ១២៥ ម នោះបញ្ជាក់ឱ្យឃើញថាតំរូវការកសាងសាលាមួយ ពីរ ទៀតមិនមានបញ្ហាចោទឡើយនៅក្នុងបរិវេណចាស់នេះ ។

ចំណោះការអភិវឌ្ឍន៍ និង ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងឃុំជ្រោយប្រស់បច្ចុប្បន្ននៅមានកំរិត ទោះជាសព្វថ្ងៃនេះសាលាបឋមសិក្សាមួយអគារ និង អនុវិទ្យាល័យ មួយអគារក៏ដោយក៏ពុំទាន់បំពេញនូវតំរូវការសិក្សា របស់សិក្សានុសិស្សឡើយជាអាទិ៍ដូចជា នៅគំរោងផែនការ ១៥ ឆ្នាំ ខាងមុខតំរូវការលើអគារសិក្សា ផ្អែកតាមបរិមាណ នៃសិស្ស គឺសាលាបឋមសិក្សា ក៏ដូចជាអនុវិទ្យាល័យ បើពិនិត្យទៅតាមការគណនាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំ ជ្រោយប្រស់ គឺរយៈពេល ១៥ ឆ្នាំ អាចតំរូវការសាលាបឋមសិក្សា ១ អគារ ០៥ បន្ទប់បន្ថែមទៀត សំរាប់ដល់ឆ្នាំ ២០២២ តំរូវការទាំងនេះអាចផ្តល់ឱកាសឱ្យឃុំអាចអភិវឌ្ឍន៍ទៅតាមលទ្ធភាព ជាបណ្តើរៗដែលក្នុងនោះសាលា បឋមសិក្សាភូមិជ្រោយប្រស់ ០១ អគារ មានគំរោងពង្រីកនារយៈពេល ១៥ ឆ្នាំ ខាងមុខរីឯអនុវិទ្យាល័យ ពុំទាន់តំរូវការនៅឡើយបើពិនិត្យតាមកំណើនសិស្សដល់ឆ្នាំ ២០២២ ។

**<u>តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២</u>**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ៥៥ | ០ | ១ | ៦៦ | ០ | ០ | ៧៧ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ៣០៣ | -១ | -៣ | ៣៦១ | ០ | ១ | ៤១៩ | ១ | ៤ |
| ថ្នាក់អនុវិទ្យាល័យ | ១៦២ | -១ | -៣ | ១៩៣ | ០ | -១ | ២២៤ | ០ | ១ |
| ថ្នាក់វិទ្យាល័យ | ១៦១ | ០ | ២ | ១៩១ | ០ | ០ | ២២២ | ០ | ២ |

## ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក. សេវាកម្មសុខភាព

បច្ចុប្បន្ន ឃុំជ្រោយប្រស់ក៏ពុំទាន់មានប៉ុស្តិ៍សុខភាពទេ មានតែពេទ្យស្ម័គ្រចិត្តចំនួន ៤នាក់ របស់អង្គការ CZM សំរាប់ព្យាបាលកុមារអាយុក្រោម ៥ ឆ្នាំ ប៉ុណ្ណោះ និង មានពេទ្យឯកជនចំនួន ០២នាក់ សំរាប់ព្យាបាលប្រជាជនក្នុងឃុំ ។

ចំពោះការបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាពដែលស្ថិតនៅក្នុងឃុំត្រពាំងរូង ឬទៅមន្ទីរពេទ្យខេត្ត ដែលមាន ចំងាយពី ៤២-៤៤ គម ជាហេតុធ្វើឱ្យមានការលំបាកក្នុងការបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដោយបញ្ជូនអ្នកជំងឺនេះធ្វើដំណើរតាមរយៈទូកតែប៉ុណ្ណោះ ។

### ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំជ្រោយប្រស់ នៅពុំទាន់បានគ្រប់គ្រាន់នឹងតំរូវការរបស់ប្រជាពលរដ្ឋនៅឡើយ ទេ ពឹងផ្អែកទៅលើទឹកភ្លៀងនៅរដូវវស្សា និង អណ្តូងលូចំនួន ១១ អណ្តូង ហើយមានអណ្តូងលូតែ ៣ ប៉ុណ្ណោះអាចប្រើបាននៅរដូវប្រាំង ។ នៅក្នុងនោះដែរឃុំមានប្រព័ន្ធចែកចាយទឹកឯកជនដែលមានស្រះចំនួន ០១

តែនៅមិនគ្រប់គ្រាន់នៅរដូវប្រាំង ដែលជាហេតុធ្វើឱ្យប្រជាជនមួយចំនួនត្រូវទៅដឹកទឹក ពីភ្នំកោះកុង ឬពីកន្លែងឆ្ងាយពីឃុំ ។

ចំពោះអណ្តូងលូចំនួន៤ត្រូវខូចខាតស្ទើរតែមិនអាជួសជុលបាន ដែលតំរូវឱ្យធ្វើការជួសជុល និង ស្តារឡើងវិញ ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៍ទៅលើផ្នែកវប្បធម៌ ជាកត្តាមួយចូលរួមចំណែកជំរុញអោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ នៅលើទីតាំងទាំង ២ នៃភូមិស្ថិតនៅជិតគ្នាត្រូវបានផ្តល់លទ្ធភាព និង ជួយសំរួលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានផ្ទាល់មានឱកាសចូលរួមពង្រីក លើការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូងនៃប្រទេសជាតិអោយជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់ ។ ជាអាទិ៍សំរាប់ឃុំជ្រោយប្រស់សំរាប់កន្លែងគោរពប្រពៃណីសាសនា ថ្ងៃអនាគតពុំមានតម្រូវការបន្ថែមឡើយ ។

**<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | ១ | ២ | ១ |
| ទីកន្លែងសក្ការៈបូជា | ១ | ១ | 0 |
| វត្តអារាម | ១ | ១ | 0 |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

បរិមាណផ្លូវដែលមានក្នុងឃុំជ្រោយប្រស់សព្វថ្ងៃមិនមានផ្លូវគ្រួសក្រហមនៅឡើយតែរយៈពេល ១៥ ឆ្នាំខាងមុខឃុំនឹងលើកគម្រោងផែនការអភិវឌ្ឍន៍ផ្លូវគ្រួសក្រហមមួយខ្សែភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ទៅឃុំជ្រោយប្រស់មានប្រវែងប្រមាណ ២២.០៧ គ.ម និងគំរោងសាងសង់ស្ពានបេតុង លើផ្លូវគ្រួសក្រហម នេះប្រមាណ ០៦ កន្លែង ។ ចំណែកផ្លូវបេតុងឃុំបានសិក្សា និង លើកគំរោងផែនការអនាគតរយៈពេល ១៥ ឆ្នាំ នេះមានប្រវែង ៥៥៥.៩៦ ម សំរាប់ប្រជាពលរដ្ឋធ្វើដំណើរតាមភូមិទៅមាត់ឆ្នេរ ។ ដោយឡែកចំពោះផ្លូវដីសដែលត្រូវបានក្លាយពីផ្លូវ ថ្មើរជើង និងផ្លូវរទេះនោះគឺឃុំបានធ្វើការសិក្សាទៅលើផ្លូវចំនួន ២ ខ្សែមានប្រវែង ១២៣៩.១១ ម ដែលផ្លូវនីមួយៗមានទិសដៅចូលទៅតាមភូមិ ដែលត្រូវបានកើតថ្មីក្នុលំនៅដ្ឋានសព្វថ្ងៃ ។

ដូចគ្នានេះដែរក្នុងដំណើរការអភិវឌ្ឍន៍ទៅលើប្រព័ន្ធស្រោចស្រពឃុំបានធ្វើការសិក្សាលើកគំរោងក្នុងនោះមានប្រឡាយមេមានប្រវែង ៣.១០ គ.ម ប្រឡាយរង ២.៧ គ.ម ទ្វារទឹកមួយកន្លែង និង ទំនប់ការពារទឹកប្រៃប្រវែង ៣.១០ គ.ម នោះទើបឃុំអាចមានលទ្ធភាពក្នុងការផ្គត់ផ្គង់ស្បៀងគ្រប់គ្រាន់ ។

តារាងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងផ្លូវឆ្នាំនេះ (គ.ម) | ប្រវែងផ្លូវ១៥ឆ្នាំ (គ.ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | 0 | 0 | 0 |
| ផ្លូវក្រាលគ្រួសក្រហម | 0 | ២៧ | ២៧ |
| ប្រវែងផ្លូវក្រាលដីស | 0 | 0 | 0 |
| ប្រវែងផ្លូវរទេះ/ថ្មើរជើង | ១.២៤ | ១.២៤ | 0 |
| ប្រឡាយមេ | 0 | ៣.២១០ | ៣.២១០ |
| ប្រឡាយរង | 0 | ២.៧00 | ២.៧00 |
| ទំនប់ទឹកប្រៃ | 0 | ៣.២១០ | ៣.២១០ |
| ទ្វារទឹក | 0 | ១ | ១ |
| ផ្លូវបេតុង | 0.៣៩0 | 0.៩៥៦ | 0.៩៥៥ |
| ផៃបេតុង | 0.២៩0 | 0 | 0 |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីអនាគត

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំជ្រោយប្រស់ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ និង អភិរក្ស អភិវឌ្ឍន៍ ទៅលើធនធានទាំងនោះអោយមាននិរន្តរភាពដែលក្នុងនោះរួមមានដូចជា :

-ព្រៃភ្នំ: ស្ថានភាពដីនៃទីព្រៃភ្នំគឺជាបរិស្ថានធម្មជាតិមួយដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានរស់នៅ នៃពពួកសត្វ ផ្តល់នូវទីជំរកដល់ពពួកសត្វទាំងឡាយ ដូចជា សត្វដំរី ខ្លាធំ ខ្លាឃ្មុំ ឈ្លូស ប្រើស ជ្រូកព្រៃនិង សត្វផ្សេងៗជាច្រើនប្រភេទ ។

-ព្រៃលិចទឹកគឺជាបរិស្ថានធម្មជាតិដ៏ប្រសើរសំរាប់មជ្ឈដ្ឋានរស់នៃធនធានជលផលក្នុងតំបន់នោះ។ នៅក្នុងក្របខ័ណ្ឌនៃការស់របស់ពពួកភាវរស់គឺជាបណ្តាអេកូឡូស៊ីនៅក្នុងមជ្ឈដ្ឋាន ទីព្រៃលិចទឹកដែលបានផ្តល់នូវប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាអាទិ៍ដូចជាព្រៃលិចទឹកផ្តល់នូវជំរកដល់ភាវរស់ និង សត្វផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹកដូចជាពពួកសត្វសំខាន់ៗ ( ក្តាមថ្ម បង្គា កន្ទាយ អណ្តើក ពស់ ស្វា អន្សង ត្រកួត និង

សត្វស្លាបជាច្រើនប្រភេទទៀត ។ ទាំងនេះគឺជាសក្តានុពលមួយដែលផ្តល់នូវសារៈប្រយោជន៏ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសំរាប់ការដកយកអនុផលពីព្រៃភ្នំ ព្រៃលិចទឹក ដូចជា វល្លិ៍ ផ្តៅ ផ្សិត ជ័រវ៉ុងផ្លែសំរ៉ង់ និង ដើមរុក្ខជាតិខ្លះយកមកធ្វើឱសថសំរាប់ព្យាបាល និង ជារបាំងការពារខ្យល់ ។

## ៣.១.២ តម្រូវការដីតាមប្រភេទ

-អត្រាកំណើនប្រជាពលរដ្ឋគឺជាការកើនឡើងនូវតម្រូវការនៃការប្រើប្រាស់ ទៅលើធនធានដូច្នេះយើងត្រូវតែធ្វើការពិចារណាធនធានដែលមាននៅក្នុងឃុំ ។

-ដីភូមិទិសដៅអនាគតឃុំមានគំរោងយកនៅចំណុចដូចខាងក្រោម :

-ចំណុចវាលក្រសារ ជាដីចំការបោះបង់ចោល ដុះស្មៅ និង មានប្រជាពលរដ្ឋរស់នៅមួយចំនួន ដីសំរាប់ភូមិនេះមានទំហំប្រមាណ ៩៥ ហិកតា ផ្នែកខាងក្រោយភូមិមានដីស្រែ បច្ចុប្បន្នប្រជាពលរដ្ឋពុំហ៊ានធ្វើស្រែចំការនៅលើដីនោះទេ ព្រោះជាតំបន់ការពារ ។ ដូច្នេះតំបន់នេះពុំមានផលប៉ះពាល់ដល់ធនធានធម្មជាតិឡើយ មានលក្ខណៈល្អក្នុងការរស់នៅ និងការបង្កបង្កើនផល ចំណុចវាលក្រសារនេះជាដីភូមិចាស់របស់ប្រជាពលរដ្ឋមួយចំនួន ជាដីស្រែ និងដីចំការទើបឃុំបង្កើតជាភូមិសំរាប់អនាគត ។

-ដីដំណាំឈើហូបផ្លែឃុំមានផែនការពង្រីកផ្ទៃដីចំនួន៣កន្លែងដែលមានទីតាំងនៅក្បែរគ្នា (ចំណុចវាលវែង ) មានទំហំសរុប១២៧.៥៧ ហិកតា សំរាប់កំណើនប្រជាពលរដ្ឋរយៈពេល ១៥ ឆ្នាំ និង សំរាប់ប្រជាពលរដ្ឋបច្ចុប្បន្នពុំមានដីកសិកម្ម ក្នុងនោះបើតាមការពិនិត្យទៅលើស្ថានភាព និងគុណភាពដី វាអាចផ្តល់នូវទិន្នផលល្អប្រសើរ ព្រោះជាដីដែលមានជីជាតិ បើទោះជាចំណាយក្នុងការកែប្រែក៏ពុំមានអ្វីធ្ងន់ធ្ងរឡើយ ។

-វាលកប់ខ្មោចជាកត្តាមួយដែលធ្វើឱ្យមានផលប៉ះពាល់ទៅដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ដូច្នេះឃុំមានគោលការណ៍រៀបចំដីនៅចំណុចវាលក្រសារក្រោយភូមិចំនួន ០១ ហិកតា សំរាប់កប់ខ្មោចនៅក្រោយភូមិដែលគ្រោងបង្កើតថ្មី ។

តំរូវការនៃការប្រើប្រាស់ដីអនាគត

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ.ហត | ក្រឡាផ្ទៃ ១៥ .ហត | បំរែបំរួល .ហត |
|---|---|---|---|
| **១- ប្រភេទនៃការប្រើប្រាស់ដីតាមប្រភេទ** | | | |
| ដីភូមិ | ២៩.៣២ | ១២៤.៣២ | ៩៥ |
| ដីវាលកប់ខ្មោច | 0 | ១ | ១ |
| ដីវាលស្រែ | ៣៣៣.៧៣ | ៣៣៣.៧៣ | 0 |
| ដីស្រែជាមួយដីភូមិ | 0 | 0 | 0 |
| ដីចំការឈើហូបផ្លែ | ២០៧.២៥ | ៣៣៤.៨២ | ១២៧.៥៧ |

| | | | |
|---|---|---|---|
| ២- ការគ្រប់គ្រង និងកាន់កាប់ដី | | | |
| ឧទ្យានជាតិបូទុមសាគរ | ២៧,៤៣៧.៣៣ | ២៦,៩៩៧.៣៣ | ៤៤0 |
| ដែនជំរកសត្វព្រៃពាមក្រសោប | ៤២៤.៩៧ | 0 | 0 |
| ក្រុមហ៊ុនគ្រីនិច | ១៨,៣៤២.៨៤ | 0 | 0 |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រងនិងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវផលប្រយោជន៍ និង មាននិរន្តរភាពហើយនឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និង បរិស្ថាន ដែលក្នុងនោះ មានដូចជា :

ការប្រែប្រួលពីដីវាលស្មៅទៅជាដីស្រែ សំរាប់ការបង្កបង្កើនផលនេះជាការពង្រីកលើវិស័យកសិកម្មវាជាកត្តា អំណោយផលដល់ការបង្កើននូវផលិតផល ក៏ដូចជា សេដ្ឋកិច្ចក្នុងមូលដ្ឋាន ។ នៅក្នុងបរិបទនេះការប្រែប្រួលប្រភេទដី ប្រសិនបើវាលស្មៅដែលជាដីស្រែដែលត្រូវបោះបង់ចោល នោះវាជាមោទនៈភាពសំរាប់ការពង្រីកលើការងារធ្វើស្រែ។ តែក្នុងករណីវាលស្មៅមានការពាក់ព័ន្ធ និង ព្រៃលិចទឹកនោះ និង ធ្វើឱ្យមានការប៉ះពាល់ដល់ធនធានធម្មជាតិ និងបាត់ បង់នូវប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ។

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងមូលដ្ឋានឃុំ គឺជាកត្តាផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និង ចរាចរគ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការ កាត់បន្ថយការចំណាយទៅលើការងារដឹកជញ្ជូន ។ ការអភិវឌ្ឍន៍នេះថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ ខ្លះៗក៏ដោយប៉ុន្តែវាផ្តល់នូវផលប្រយោជន៍ច្រើនដល់ប្រជាជនប្រើប្រាស់ ។

-ការសាងសង់ប្រឡាយដើម្បីធានាដល់ការស្រោចស្រពក៏ដូចជាកត្តាផ្តល់នូវសារៈប្រយោជន៍ ក្នុងការបង្កើន នូវប្រាក់ចំណូលតាមរយៈការបង្កបង្កើនផល និង ដំណាំរួមផ្សំ ។ នៅក្នុងឃុំជ្រោយប្រស់តម្រូវការមានទំនប់ និងទ្វារទឹកទប់ទឹកប្រៃព្រោះជាកត្តាសំខាន់ក្នុងការហូរចូលទឹកប្រៃលើដីស្រែធ្វើឱ្យខូចគុណភាពដី ។ ដោយឡែកចំពោះ ការពង្រីកវិស័យអប់រំដោយផ្តោតទៅលើ ការពង្រីកអគារសិក្សា និង សាលា គឺជាការ ចាំបាច់បំផុតសំរាប់ការបង្កើន ធនធានមនុស្សនៅក្នុងមូលដ្ឋាន ។ ទៅថ្ងៃអនាគតទោះបីឃុំមានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់ បឋមសិក្សា និង អនុវិទ្យាល័យ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់នៅមានដីដែលអាចសាងសង់អគារសិក្សា បន្ថែមបាន។

## ៣.២.២ ផែនទីប្រើប្រាស់ដីពេលអនាគត




## ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុង ឃុំជ្រោយប្រស់ត្រូវបានបែងចែក ទៅតាមគោលការណ៍មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័តហើយបានអនុលោមទៅតាមមុខនាទីដូចខាងក្រោម :

- ការប្រើប្រាស់សំរាប់ដីលំនៅដ្ឋាន ឬ ដីភូមិ គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋានដោយមាន ការដាំដំណាំ រួមផ្សំ ដូចជា ដូង ស្វាយ ខ្នុរ មង្ឃុត ធុរ៉េន ។ ជាមួយគ្នានេះដែរប្រភេទដីលំនៅដ្ឋានអាចមានដីស្រែដែលមានលក្ខណៈជាដីសំណាប ឬជាដីដាំដំណាំរយៈពេលខ្លីដូចជា ពោត សណ្តែក ត្រឡាច ល្ពៅ អំពៅ ដំឡូង ស្ពៃ គ្រប់ប្រភេទ ។

នៅក្នុងការប្រែប្រួលនូវប្រភេទដីពីដីវាលស្មៅ ដីភូមិចាស់មកជាដីលំនៅដ្ឋានតាមរយៈនៃការរីករាលដាលប្រជាពលរដ្ឋដោយការបែងចែកកេរ្តិ៍ទុកអោយកូន។ រីឯស្ថានភាពនៃការរីកដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវ ឬតាមប្រភពទឹក ។ ការបង្កើតលំនៅដ្ឋានថ្មីតូចធំនៅតាមស្ថានភាពដីដែលឪពុកម្តាយចែកឱ្យ។

-ការប្រើប្រាស់ដីសំរាប់បង្កើតដីស្រែនៅក្នុងឃុំជ្រោយប្រស់គឺអនុវត្តបានតែ ១ ដងសំរាប់ស្រូវសន្ទូងរដូវវស្សាព្រោះមានប្រភពទឹកដើម្បីស្រោចស្រពលើដីស្រែនៅរដូវប្រាំង ។

ការប្រែប្រួលក៏ដូចជាការកើនឡើង នៃប្រភេទដីស្រែនេះ គឺជាការពង្រីកទៅលើដីវាលស្មៅស្រែចាស់ដែលបានបោះបង់ចោលពីមុនមកនោះ ត្រូវបានធ្វើការរៀបចំកែលំអឡើងវិញដោយធ្វើការកែលំអទៅតាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវដល់ប្រជាពលរដ្ឋ ដើម្បីផ្តល់ឱកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ។ ផ្អែកទៅតាមស្ថានភាពដីវាលស្មៅបច្ចុប្បន្នមានសណ្ឋានជាប់ទៅនឹងដីទីព្រៃលិចទឹក ប៉ុន្តែចំពោះដីប្រភេទនេះយើងត្រូវធ្វើកាផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវដើម្បីចៀសវាងការវាតដីចូលទៅក្នុងដីនាទីព្រៃលិចទឹក ព្រោះនាទីព្រៃលិចទឹកពុំទាន់មានព្រំប្រទល់ច្បាស់លាស់នៅឡើយ ។ សូមបញ្ជាក់ផងដែរថាចំពោះផែនការកែប្រែដីវាលស្មៅឱ្យទៅជាដីស្រែឃុំពុំមានគោលការណ៏យកដីស្មៅដែលស្ថិតនៅក្នុងនាទីព្រៃលិចទឹកមកធ្វើការអភិវឌ្ឍន៏ឡើយ ។

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិទឹក ( ដីសាធារណៈរបស់រដ្ឋ )គឺត្រូវទាមទារការថែរក្សាអោយ បានគង់វង់ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍន៏ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៏ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

-នៅក្នុងការប្រែប្រួលពីដីវាលស្មៅទៅជាដីដែលមានព្រៃលិចទឹក គឺជាអាទិភាពដោសារដីព្រៃប្រភេទវាលស្មៅដែលស្ថិតក្នុងនាទីព្រៃលិចទឹក គឺជាព្រៃលិចទឹកដែលបានឆេះកន្លងមកក្លាយជាវាលស្មៅ ដូច្នេះជាគោលការណ៏ត្រូវការពារ ថែរក្សាទុកឱ្យព្រៃលិចទឹកដុះឡើងវិញដើម្បីធានាធនធានក្នុងតំបន់ ។

-ការប្រើប្រាស់ដីផ្ទៃទឹកនានាក្នុងឃុំគឺជាកត្តាចំបងសំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដើម្បីបំរើផលប្រយោជន៏ ឱ្យវិស័យកសិកម្ម និង ការប្រើប្រាស់ទូទៅផ្អែកទៅតាមធនធានទឹកដែលមាននៅក្នុងឃុំរួមមានឃុំអាចមានលទ្ធភាពក្នុងការដកយកមកប្រើប្រាស់បានតែប្រភេទទឹកបឹងតែប៉ុណ្ណោះ ដោយឡែកចំពោះប្រព័ន្ធប្រឡាយបច្ចុប្បន្នពុំអាចមានលទ្ធភាពក្នុងការប្រើប្រាស់បានឡើយ ( ប្រឡាយរីងរាក់) ។

-ការប្រែប្រួលពីដីស្រែមកជាដីប្រពន្ធ័ប្រឡាយ ឬដីប្រឡាយចាស់មកជាប្រឡាយថ្មី ជាបញ្ហាចោទព្រោះថាមានបញ្ហាលំបាកសំរាប់ការដោះស្រាយនូវបញ្ហាប្រឈម ដោយបច្ចុប្បន្នមានបញ្ហាប្រឈមមួយចំនួន នឹងត្រូវកើតមានឡើងក្នុងពេលប្រឡាយចាប់ផ្តើមសាងសង់ និង ស្តារ ដូចជាការរំលោភយកដីប្រឡាយធ្វើស្រែ ហើយបញ្ហាមួយទៀតក្នុងករណីមានការសាងសង់ប្រឡាយថ្មីបញ្ហានឹងកើតឡើងដោយការមិនយល់ពីសារៈប្រយោជន៏ក្នុងការប្រើប្រាស់ប្រឡាយ ដូចជាបញ្ហានៃការប៉ះពាល់ដីស្រែធ្វើឱ្យឃុំប្រឈមក្នុងការដោះស្រាយ ។

-ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅលើផ្ទៃទឹកសមុទ្រ ត្រូវបានប្រើប្រាស់ធនធានដែលមាននៅ ក្នុងមូលដ្ឋានដូចជារករបរនេសាទនៅលើដែននេសាទដោយមានការ កាពារ ថែរក្សា និង អភិរក្ស ។ ប៉ុន្តែកត្តានេះមានការពាក់ព័ន្ធទៅនឹងផលប៉ះពាល់បរិស្ថានដូច្នេះនៅពេលអនាគត ប្រសិនបើរាជរដ្ឋាភិបាលមានគោលការណ៏ឱ្យប្រជាជនដែលរស់នៅលើផ្ទៃទឹកសមុទ្រត្រូវផ្លាស់ប្តូរលំនៅដ្ឋានមករស់ផ្អែកខាងលើគោកវិញ ឃុំនឹងធ្វើការចូលរួមរកដំណោះស្រាយឱ្យសមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ចំពោះប្រជាពលរដ្ឋដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ

(ដីមាត់សមុទ្រ) បច្ចុប្បន្នអ្នកដែលរស់នៅចាស់មានការលំបាកក្នុងការផ្លាស់ប្តូរប៉ុន្តែជាគោលការណ៍ឃុំធ្វើការហាមឃាត់ការសាងសង់លំនៅដ្ឋានថ្មី ។

-ការប្រើប្រាស់ដីសំរាប់កសាងផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបាន ព្រោះថាផ្លូវដែលកើតឡើងគឺជាកត្តាផ្តើមចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើឱ្យកើតមានផ្លូវជាដំបូងហើយឃុំក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងឃុំគឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។

### ៣.២.៣.១ ដីលំនៅដ្ឋាន (បញ្ញត្តិគោលការនៃការប្រើប្រាស់ដី)

តាមស្ថានភាពជាក់ស្តែងដែលបានគ្រោងទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋ ២៣០ គ្រួសារ និងគ្រួសារបច្ចុប្បន្នពុំទាន់មានដីលំនៅដ្ឋាន ១៥០ គ្រួសារទៀតសំរាប់រយៈពេល ១៥ឆ្នាំខាងមុខ ប៉ុន្តែនៅក្នុងការគិតគូរទៅលើការកំណត់ នៅលើផ្ទៃដីភូមិក្នុងមួយគ្រួសារ ២៥០០ម៉ែត្រការ៉េ (យោងតាមច្បាប់ដីសម្បទានសង្គមកិច្ច) នោះឃុំអាចមានលទ្ធភាពបំពេញតម្រូវការដី៩៥,០០ ហិកតា តាមអត្រាកំណើនប្រជាពលរដ្ឋ៣៨០ គ្រួសារ ។ ដូច្នេះការកំណត់តម្រូវការដីភូមិក្នុងឃុំជ្រោយប្រស់ដែលបានគ្រោងគ្រប់តម្រូវការ ។

-ទីតាំងដីលេខកូដ F.១២០០,០១

នៅក្នុងភូមិជ្រោយប្រស់ដែលមានលេខកូដ F.១២០០,០១ ត្រូវបានកំណត់លើការពង្រីកដីលំនៅដ្ឋានដែលមានទំហំ ៩៥.០១ ហិកតា ដែលក្នុងនោះគ្រោងសំរាប់ប្រជាពលរដ្ឋចំនួន៣៨០ គ្រួសារ ហើយអនុវត្តសំរាប់រយៈពេល៥ឆ្នាំទី១ មានទំហំ ៥៤ ហិកតា សំរាប់ប្រជាពលរដ្ឋ២១៦ គ្រួសារ ៥ឆ្នាំទី២ ចំនួន២០.៥ហិកតា សំរាប់ប្រជាពលរដ្ឋ ៨២ គ្រួសារ ៥ឆ្នាំទី៣ ចំនួន ២០.៥ ហិកតា សំរាប់ប្រជាពលរដ្ឋ ៨២ គ្រួសារ ប្រភេទនៃការបែងចែកត្រូវបានកំណត់ក្បាលដី ២៥ ម x១០០ម តាមការកំណត់នេះគឺត្រូវបានគិតគូរផ្អែកតាមបណ្តោយផ្លូវដែលបានគ្រោង និង ធ្វើការសាងសង់ ។

នៅក្នុងការប្រែប្រួលនូវប្រភេទដីពីចំការភូមិចាស់ដីវាលស្មៅមកជាដីលំនៅដ្ឋានតាមរយៈនៃការរីករាលដាលនៃគ្រួសាររបស់ប្រជាពលរដ្ឋដោយការបែងចែកកេរ្តិ៍ទុកអោយកូន និង ការលក់ដោះដូរជាប្រាក់លើដីដែលមានការកាន់កាប់មួយចំនួនក្រៅពីនោះជាទ្រព្យសាធារណៈរបស់រដ្ឋសំរាប់ធ្វើការបែងចែកដល់ប្រជាពលរដ្ឋសង់លំនៅដ្ឋាន ឬ ជាដីភូមិ ។ រីឯស្ថានភាពរីករាលដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវ ឬ តាមប្រភពទឹកផ្សេងៗ ។ ការបង្កើតលំនៅដ្ឋានថ្មីតូច ឬ ធំទៅតាមស្ថានភាពដីដែលឪពុកម្តាយចែកអោយ ឬ បានមកពីការបែងចែកពីរដ្ឋអំណាចមូលដ្ឋាន ។

### បញ្ញត្តិការប្រើប្រាស់សំរាប់សង់លំនៅដ្ឋានថ្មីគឺ :

នៅក្នុងការពង្រីកដីលំនៅដ្ឋានឃុំមានគោលការណ៍រៀបចំដីភូមិដែលមានការកំណត់ និង ជំរុញអោយមានដីភូមិដែលមានសណ្តាប់ធ្នាប់សាធារណៈល្អហើយក្នុងនោះត្រូវបានអនុវត្ត :

-រាល់ដីភូមិដែលត្រូវរៀបចំថ្មី ត្រូវបានកំណត់ទុកដីចំណីផ្លូវស្របតាមច្បាប់កំណត់

-ចំពោះដីភូមិដែលត្រូវរៀបចំថ្មីនៅតាមមាត់ព្រែក ឬ អូរតាមការកំណត់នៃច្បាប់

-ការសាងសង់លំនៅដ្ឋានថ្មី នៅក្បែរដីព្រៃការពារត្រូវចេះជួយថែរក្សានូវធនធានធម្មជាតិទាំងឡាយដែលមាននៅក្នុងព្រៃ

-ការសាងសង់លំនៅដ្ឋានក្នុងភូមិត្រូវអនុវត្តទៅតាមច្បាប់អនុញ្ញាត

-ជំរៅដីសំរាប់លំនៅដ្ឋានមិនអាចលើសពី១០០ម គិតពីអ័ក្សផ្លូវដែលបានគ្រោង

-មិនត្រូវសង់លំនៅដ្ឋានលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត

-រាល់ដីភូមិដែលកើតថ្មី ត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ព័ន្ធហើយត្រូវបានបោះបង្គោលរបងកំណត់ព្រំច្បាស់លាស់ ។

### ៣.២.៣.២ ដីចំការដំណាំ

នៅក្នុងឃុំជ្រោយប្រស់ឃុំបានគ្រោងដីសំរាប់រយៈពេល១៥ឆ្នាំ មាន៣ចំនុចដែលមានទីតាំងនៅជិតៗគ្នាក្នុងភូមិជ្រោយប្រស់ចំនុចវាលវែងមានដីទំហំសរុប ១២៧.៥៧ ហិកតា សំរាប់ប្រជាពលរដ្ឋ ៨៥ គ្រួសារ F.២២០០,០២ F.២២០០,០៣ ត្រូវបានកំណត់លើការពង្រីកដីចំការដំណាំ ក្នុងការអនុវត្តន៏សំរាប់៥ឆ្នាំទី១ មានទំហំ ៤៣.៥០ សំរាប់ប្រជាពលរដ្ឋ២៩ គ្រួសារ ៥ឆ្នាំទី២មានទំហំ៤២.៥២៣ សំរាប់ប្រជាពលរដ្ឋ ២៨ គ្រួសារ និង គ្រោងសំរាប់៥ឆ្នាំទី៣ មានទំហំ ៤២.៥២៣ សំរាប់ប្រជាពលរដ្ឋ ២៨ គ្រួសារ ( ប្រភេទនៃការបែងចែកត្រូវបានកំណត់លើក្បាលដី ១០០ ម x១៥០ម ) គិតតាមបណ្តោយផ្លូវលំដែលបានគ្រោង ។

### គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម

នៅក្នុងកិច្ចអភិវឌ្ឍន៏សំរាប់ពេលអនាគតឃុំ មានគោលការណ៏ក្នុងការរៀបចំនៅការបង្កីនផលិតកម្មដំណាំស្រូវដែលក្នុងនោះត្រូវអនុវត្តនូវយុទ្ធសាស្រ្តមួយចំនួនដែលអាចជួយដល់ការបង្កើនផលិតភាពកសិកម្មគឺ :

-លើកភ្លឺដើម្បីរក្សាទឹកនៅរដូវវស្សា

-លើកកំពស់ការប្រើប្រាស់ជីធម្មជាតិ ជីកំប៉ុស្តិ៍

-កាត់បន្ថយការប្រើប្រាស់ជីគីមី

-កាត់បន្ថយការប្រើថ្នាំពុលជំរុញការអនុវត្តកម្មវិធី IPM

-រៀបចំប្រពលវប្បកម្មដំណាំស្រូវ ( ប វ ស )

-អភិវឌ្ឍន៏លើការស្តារដីស្រែចាស់អោយអស់នូវផ្ទៃដីស្រែដែលមាន

-បង្កើនការដាំដុះដំណាំចំការគ្រប់ប្រភេទ ដើម្បីអោយការប្រើប្រាស់មានប្រសិទ្ធភាពឃុំបានកំណត់ដូចខាងក្រោម :

-ហាមដាច់ខាងការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ

-ហាមឃាត់ដាច់ខាតការវាតដីស្រែចូលបឹង ឬ ប្រឡាយ

-ហាមឃាត់ដាច់ខាតការកាប់រានចូលដីនាទីព្រៃលិចទឹកដើម្បីធ្វើស្រែ

-រាល់ដីស្រែត្រូវមានភ្លឺសំរាប់សំគាល់ព្រំប្រទល់ច្បាស់លាស់

-ហាមការប្រើប្រាស់ថ្នាំពុលលើដីស្រែដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ

### ៣.២.៣.៣ ការប្រើប្រាស់ទឹក និង ប្រព័ន្ធស្រោចស្រព

ការប្រើប្រាស់ដីផ្ទៃទឹកនានានៅក្នុងឃុំគឺជាកត្តាចំបងសំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដើម្បី បំរើផលប្រយោជន៍អោយវិស័យកសិកម្ម និង ការប្រើប្រាស់ទូទៅផ្អែកតាមធនធានទឹកដែលមាននៅក្នុងឃុំ ឃុំមានលទ្ធភាពក្នុងការដកយកមកប្រើប្រាស់បានតែប្រភេទទឹកអណ្តូង និង ទឹកស្រះតែប៉ុណ្ណោះ ដោយឡែកចំពោះប្រព័ន្ធប្រឡាយបច្ចុប្បន្នគឺមានទ្រង់ទ្រាយតូចហើយរាក់ ម្យ៉ាងវិញទៀតចំពោះទំនប់ទឹកប្រៃដែលបានគ្រោងទុកនោះ គឺដើម្បីទប់ទឹកប្រៃហូរចូលមកក្នុងដីស្រែតែប៉ុណ្ណោះ ។

-ទីតាំងនៃការសាងសង់ទំនប់ទឹកប្រៃមានលេខកូដ F D N ៦៤-០១ ជាមួយ និងគំរោងផែនការក្នុងការសាងសង់ទំនប់ការពារទឹកប្រៃ ប្រឡាយមេ ប្រឡាយរង ទ្វារទឹកគឺពុំអាចផ្តោតជាសំខាន់តាមតម្រូវការនៃការសាងសង់ទំនប់ការពារទឹកប្រៃមានប្រវែងសរុប ៣,២២៤.៥៤ ម ដោយបានកំណត់ការអនុវត្តន៍សំរាប់៥ឆ្នាំទីមួយប្រវែង ១,០៧៤.៨៤ ម សំរាប់៥ឆ្នាំទី២ ប្រវែង ១,០៧៤.៨៤ ម និង ៥ឆ្នាំទី៣មានប្រវែង ១,០៧៤.៨៤ ម ។

-ទីតាំងនៃការសាងសង់ប្រឡាយមេមានលេខកូដ F D N ៥៧-០១ ក្នុងដំណើរការអភិវឌ្ឍន៍លើការសាងសង់ប្រឡាយមេឃុំបានគ្រោងអនុវត្ត២ដំណាក់កាល ៥ឆ្នាំទី១មានប្រវែង ១,៥៩៦.១ ម ៥ឆ្នាំទី២ប្រវែង ១,៥៩៦.១ ម ។

-ទីតាំងនៃការសាងសង់ប្រឡាយរងមានលេខកូដ F D N ៥៦-០២ , F D N ៥៦-០១

-ក្នុងការអភិវឌ្ឍន៍លើការសាងសង់ប្រឡាយរងឃុំបានគ្រោងអនុវត្ត២ដំណាក់កាល៥ឆ្នាំទី១ មានប្រវែង ១,១៣៩.២២ ម ៥ឆ្នាំទី២មានលេខកូដ F D N ៥៦-០១ មានប្រវែង ១,១៣៩.២២ ម ។

### ៣.២.៣.៤ ការប្រើប្រាស់ផ្លូវថ្នល់

ការប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ក៏មានបញ្ហាខ្លះដែរប៉ុន្តែអាចដោះស្រាយបាន ព្រោះថាផ្លូវដែលកើតឡើងគឺចេញពីប្រជាជនផ្ទាល់ដែលជាអ្នកធ្វើអោយកើតមានផ្លូវជាដំបូងហើយឃុំ ក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងឃុំគឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ដូច្នេះ ដំណោះស្រាយអាចដោះស្រាយបាន ។

### ៣.២.៣.៥ ទីតាំងផ្លូវក្រាលគ្រួសក្រហមលេខកូដ F R D ៣-០១

ក្នុងដំណើរការអភិវឌ្ឍន៍លើផ្លូវថ្នល់ក្រាលគ្រួសក្រហមចំនួន០១ខ្សែ ឃុំធ្វើការកំណត់ជាដំណាក់កាល៥ឆ្នាំទី១ សាងសង់លើផ្លូវបង្កើតថ្មីស្ថិតក្នុងភូមិជ្រោយប្រស់ដែលមានប្រវែង ៧,៣៥៦ ម ៥ឆ្នាំទី២ប្រវែង ៧,៣៥៦ ម ៥ឆ្នាំទី៣ប្រវែង ៧,២៥៦ ម ។

-ទីតាំងផ្លូវលំចាក់ដីសលេខកូដ F R D ៥-១ , F R D ៥-២ ចំពោះការអភិវឌ្ឍន៏សាងសង់ផ្លូវលំត្រូវបាន អនុវត្តទៅលើផ្លូវចាស់ និង ផ្លូវបង្កើតថ្មីលើផ្លូវលំថ្មើរជើងមាន២ខ្សែ ដែលក្នុងនោះនៅភូមិថ្មីមានលេខកូដ F R D ៥-១ មានប្រវែង ៤៤៥.១០ ម សំរាប់អនុវត្ត៥ឆ្នាំទី១ និងនៅភូមិជ្រោយប្រស់មានលេខកូដ F R D ៥-២ មានប្រវែង ៣៩៧ ម សំរាប់អនុវត្ត៥ឆ្នាំទី២ និងលេខកូដ F R D ៥-២ ដែលមានប្រវែង ៣៩៧ ម សំរាប់អនុវត្ត៥ឆ្នាំទី៣ ។

-ទីតាំងផ្លូវបេតុងលេខកូដ F R D ៩-០១ , F R D ៩-០២ ចំពោះការអភិវឌ្ឍន៏នៃការកសាងផ្លូវបេតុង អនុវត្តនៅតាមមាត់ឆ្នេរក្នុងភូមិថ្មីដែលមានលេខកូដ F R D ៩-០១ ជាពីរដំណាក់កាលសំរាប់៥ឆ្នាំទី១ប្រវែង ២៩៥.១៦ ម ៥ឆ្នាំទី២ មានប្រវែង ២៩៥.១៦ ម និង ក្នុងភូមិជ្រោយប្រស់មានលេខកូដ F R D ៩-០២ មានប្រវែង ៤៥.៦៤ ម សំរាប់៥ឆ្នាំទី៣ ។

### បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់

ក្នុងលក្ខណៈបច្ចេកទេសនៃការសាងសង់ផ្លូវត្រូវបានកំណត់សំរាប់ផ្លូវដូចខាងក្រោម :

-ផ្លូវក្រាលគ្រួសក្រហមក្នុងក្របខ័ណ្ឌមូលដ្ឋានឃុំត្រូវទុកដីចំណីផ្លូវ ៧ ម សងខាងផ្លូវ

-ការកំណត់លើការប្រើប្រាស់ផ្លូវថ្នល់ត្រូវអនុលោមទៅតាមច្បាប់

-បង្កើតសហគមន៏ថែទាំផ្លូវដោយមានចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន

-ហាមការដឹកជញ្ជូនលើសទំងន់

-ហាមការយក គោ ក្របី ជ្រូក ចងលើផ្លូវ

-រៀបចំស្លាកសញ្ញាចរាចរណ៏តាមបណ្តោយផ្លូវ

## ៣.២.៣.៦ ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់

នៅក្នុងឃុំជ្រោយប្រស់ដោយតម្រូវការអគារសិក្សាសំរាប់សាលាបឋមសិក្សាត្រូវបានគ្រោងបង្កើតសាលា និង សាងសង់អគារបន្ថែមដែលក្នុងនោះ :

-សាលាបឋមសិក្សាគ្រោងសាងសង់មួយអគារក្នុងភូមិជ្រោយប្រស់ក្នុង៥ឆ្នាំទី៣

-សំរាប់អគារដែលត្រូវសាងសង់កំណត់មួយអគារ៥បន្ទប់បឋមសិក្សា និង អនុវិទ្យាល័យម្យ៉ាងវិញទៀត ប្រសិនបើក្នុងករណីមានការគាំទ្រណាមួយ ដែលមានលទ្ធភាពក្នុងការសាងសង់អគារមួយខ្នងពីរជាន់១០បន្ទប់នោះកាន់តែល្អហើយឃុំ និង មានការគាំទ្រជានិច្ច ។

## ៣.២.៣.៧ ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន

-ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណ:របស់រដ្ឋ)គឺត្រូវទាមទារអោយការថែរក្សាអោយបាន គង់វង្សដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារថែរក្សាអភិរក្ស និង អភិវឌ្ឍន៏ទៅលើធនធានទាំងនោះ ដើម្បីផ្តល់នូវផលប្រយោជន៏ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយ:ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ។

នៅក្នុងការប្រែប្រួលដីវាលស្មៅទៅជាដីដែលមានព្រៃលិចទឹកនោះ គឺជាអាទិភាពដោយសារដីប្រភេទវាលស្មៅ ដែលស្ថិតក្នុងនាទីព្រៃលិចទឹកគឺដីព្រៃលិចទឹកដែលបានឆេះ កន្លងមកក្លាយជាវាលស្មៅដូច្នេះជាគោលការណ៍ត្រូវការពារ ថែរក្សាទុកអោយព្រៃលិចទឹកដុះឡើងវិញដើម្បីធានាធនធានក្នុងតំបន់ ។

នៅក្នុងដំណើការនៃការការពារធនធានធម្មជាតិនៅឃុំជ្រោយប្រស់ត្រូវបានអនុវត្ត និង កំណត់ទៅតាម ក្របខ័ណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័ននីមួយៗ ដូចជាឧទ្យានជាតិបូទុមសាគរដែលមានផ្ទៃក្រឡា ២៧,៤៣៧.៣៣ ហិកតា និងដែនជំរកសត្វព្រៃពាមក្រសោប ដែលមានផ្ទៃក្រឡា ៤២៤.៩៧ ហិកតា ។ ហើយជាមួយគ្នានេះដែរឃុំមាននាទីព្រៃលិចទឹក ដែលជាជំរកដ៏ប្រសើរសំរាប់ធនធានជលផលដូច្នេះដើម្បីធានានូវ សុវត្ថិភាពស្បៀង និង និរន្តរភាពធនធានធម្មជាតិក្នុងតំបន់ឃុំ បានយកចិត្តទុកដាក់ចូលរួមការពារ និង ថែរក្សាអោយ មានស្ថេរភាពយូរអង្វែង ។

-នៅក្នុងការការពារប្រភពធនធានជលផលដូចជាតំបន់ជំរកត្រីពងកូន

-កំណត់កន្លែងអភិរក្សព្រៃលិចទឹក ( ការពារថែរក្សាព្រៃលិចទឹក និង សត្វគ្រប់ប្រភេទ )

**បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ធនធាន**

នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានឃុំត្រូវបានរៀបចំគ្រប់គ្រង និង ប្រើប្រាស់ទៅលើព្រៃ លិចទឹកដែលក្នុងនោះត្រូវបែងចែក

-កំណត់ការដកយកផល និង អនុផលព្រៃឈើ ព្រៃលិចទឹក

-ហាមការចាប់សត្វព្រៃគ្រប់ប្រភេទនៅក្នុងដែនអភិរក្ស

-ហាមការចាប់សត្វដែលច្បាប់ជលផលបានកំណត់

-ហាមកាប់អុសក្នុងព្រៃអភិរក្ស និង ព្រៃលិចទឹក

-ហាមការកាប់រានដីព្រៃការពារ និង ព្រៃលិចទឹក

-ហាមការធ្វើស្រែក្នុងបឹង និង អូរ

-ហាមការបូមពង្រីងបឹងដើម្បីចាប់ត្រី

ឃុំជ្រោយប្រស់,ថ្ងៃទី....12.......ខែ......5.......ឆ្នាំ 2010.......

**មេឃុំ**

ពុំ ឡឿន

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋខេត្តកោះកុង

"ដើម្បីមេត្តាពិនិត្យ និង សំរេច"

កោះកុង,ថ្ងៃទី...12.....ខែ....5.....ឆ្នាំ ..2010.

**អភិបាលនៃគណៈអភិបាលស្រុក**

**និង ប្រធានក្រុមការងារជីវដ្ឋ**

**ស្រុកកោះកុង**

សោម_សុធីរ

**បានឃើញ និង ឯកភាព**

កោះកុង,ថ្ងៃទី....១៥.....ខែ....ឧសភា....ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវដ្ឋ**

**ខេត្តកោះកុង**

ប៊ុន លើក

## ឧបសម្ព័ន្ធ ១

## ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានភូមិ:**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំ នៅក្នុងមូលដ្ឋានឃុំជ្រោយប្រស់លាតសន្ធឹងលើផ្ទៃដី ២៩.៣២ ហិកតា នៅទីតាំងភូមិសំបូរទៅដោយដើមស្វាយ ខ្នុរ សាវម៉ាវ ដូង កំពីងរាជ ....។ល។ ក្នុងឃុំជ្រោយប្រស់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋភូមិជ្រោយប្រស់ និង ភូមិថ្មីគាគច្រើននៅតាមឆ្នេរសមុទ្រ នៅតាមទីខ្ពស់ពុំសូវមានផ្ទះ និងសួនដំណាំឡើយ ។

- **ដីស្រែវស្សា :**

**+ដីស្រែវស្សា :**

ដីស្រែវស្សា នៅឃុំជ្រោយប្រស់ធ្វើបានតែមួយរដូវតែប៉ុណ្ណោះ ហើយការធ្វើស្រែវស្សានោះ ពឹងទៅលើទឹកភ្លៀងតែមួយមុខប៉ុណ្ណោះ ។ រីឯទិន្នផលបាន ១.៥ តោនទៅ ២ តោនក្នុង ១ ហិកតា ពូជស្រូវដែលប្រជាជនធ្លាប់ធ្វើបច្ចុប្បន្នពូជស្រូវផ្កាខ្ញី ផ្កាម្លិះ សម្បុកអង្រង ស្រូវក្រហម ។

ដីស្រែវស្សាបច្ចុប្បន្នក៏នៅមិនទាន់បំរើបាននូវសេចក្តីត្រូវការប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ ព្រោះវានៅមានបញ្ហាចោទខ្វះទឹក ប្រព័ន្ធប្រឡាយ ភ្លឺ ទំនប់ការពារទឹកប្រៃហូរចូល ដែលជាកត្តាធ្វើឱ្យប្រជាជននៅឃុំជ្រោយប្រស់ធ្វើស្រែមិនបានអស់ដីស្រែ ឬធ្វើឱ្យមានការខូចខាតមិនទទួលបានទិន្នផល ។

+ចំការដំណាំ

បើពិនិត្យទៅលើចំការដំណាំវិញឃើញថា ទូទាំងឃុំមានប្រជាជនធ្វើបន្តិចបន្តួចទៅលើផ្ទៃដីប្រមាណ ៧.២៩ ហិកតា នៅលើទួលមានដំណាំពោត ដំឡូងឈ្វា ដំឡូងឈើ ឪឡឹក តែទិន្នផលពុំសូវបានប៉ុន្មានឡើយ ព្រោះធ្វើនេះពឹងលើធម្មជាតិពុំមានទឹកស្រោចស្រពឡើយ ។ ម្យ៉ាងវិញទៀតសត្វល្អិតបំផ្លាញការដាំដំណាំរបស់ប្រជាពលរដ្ឋក្នុងឃុំជ្រោយប្រស់គ្រាន់តែជួយដោះស្រាយជីវភាពខ្វះៗពុំបានលក់ដូរអ្វីឡើយ ។

+ចំការឈើហូបផ្លែ

ចំការឈើហូបផ្លែលាតសន្ធឹងលើផ្ទៃដី ២០០ ហិកតា ដីគ្រួសក្រហមកណ្តោងល្បាយខ្សាច់ដែលល្អសំរាប់ដំណាំដូចជា ធុរេន កំពីងរាជ សាវម៉ាវ ខ្នុរ ស្វាយ ...។ល។ ចំការទាំងនេះច្រើននៅទីជំរាលភ្នំ ទីទួលមានប្រភពទឹកតែនៅរដូវប្រាំងប្រើមិនគ្រប់គ្រាន់ឡើយ ។ រីឯផលដំណាំរបស់ប្រជាពលរដ្ឋក្នុងឆ្នាំនេះមានប៉ុន្មានគ្រួសារបានលក់ដូរដូចជា ធុរ៉េន សាវម៉ាវ តែមិនច្រើនប៉ុន្មានឡើយ ។ ការដាំនៅតំបន់នោះភាគច្រើនដាំគ្រាន់តែសំរាប់ហូបប៉ុណ្ណោះ ។ ប្រសិនបើពេលអនាគត ឃុំជ្រោយប្រស់ប្រជាពលរដ្ឋក្នុងឃុំមានសំភារៈគ្រប់គ្រាន់ក្នុងការដាំដុះដូចជា ត្រាក់ទ័រ ភ្ជួររាស់ គោក្របី នោះជីវភាពបានធូធារមួយក៏រិតថែមទៀត ។

+ដីកសិកម្មពនេចរ

ដីប្រភេទនេះបច្ចុប្បន្នវាស្ទើរតែអស់ទៅហើយ ព្រោះការធ្វើបែបនេះវាចាស់គឺរិលបុរាណពេក វាជាទំលាប់របស់ប្រជាជនមួយចំនួនគាត់ទន្រ្ទានកាប់ព្រៃម្តងកន្លែងនេះ ម្តងកន្លែងនោះវិលជុំដើម្បីដាំស្រូវចិញ្ចឹមជីវិតរបស់ពួកគាត់ ។ វាស្របទៅនឹងច្បាប់របស់ពួកយើងឱ្យកែប្រែទំលាប់បែបនេះព្រោះវាបំផ្លាញធនធានធម្មជាតិច្រើន មកធ្វើស្រែចំការអចិន្ត្រៃយ៍វិញ ។ ផ្ទៃដីចំការដែលនៅសេះសល់ដល់សព្វថ្ងៃប្រមាណ ៣.៩៦ ហិកតា តែពេលបច្ចុប្បន្ននិងទៅអនាគតប្រជាជនឃុំជ្រោយប្រស់ បែរមកធ្វើស្រែចំការអចិន្ត្រៃយ៍វិញ ។

+ដីព្រៃលាយដីចំការ ដីកសិកម្ម

ដីប្រភេទនេះភាគច្រើនជាដីភូមិចំការចាស់ដែលបន្សល់ទុកនៅតាំងពីសង្គមរាស្ត្រនិយម ។ រហូតមកដល់សព្វថ្ងៃដំណាំចាស់ដូចជា ដូង ស្វាយ ខ្នុរ និង ដីស្រែមួយចំនួន កន្លែងខ្លះប្រជាជនកំពុងធ្វើនៅចំណុចវាលវែង ព្រែកកាទី វាលក្រសារ ។

+ព្រៃស្រោង ( សើម)

ឃុំជ្រោយប្រស់ជាឃុំដែលស្ថិតក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ សំបូរទៅដោយព្រៃស្រោងក្រាស់ដែលមានទំហំ ៣២,៦៩២.២៤ ហត ដែលឱ្យផ្តល់នូវសក្តានុពលខាងវិស័យទេសចរណ៏ធម្មជាតិ ។

+ព្រៃដុះឡើងវិញ

រយៈកន្លងមកភាពអនាធិបតេយ្យក្នុងការកាប់បំផ្លាញព្រៃឈើធ្វើអាជីវកម្មក្នុងអំឡុងឆ្នាំ ១៩៩៨ ដល់ឆ្នាំ ១៩៩៩ មានភាពរេចរឹលមួយចំនួន ក្រោយមកទៀតមិនមានការកាប់ទន្រ្ទានយកដីទុកលក់ តែដោយមានបទបញ្ជារបស់រាជរដ្ឋាភិបាលមានវិធានការទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ ក្រោយមកព្រៃឈើមានដុះឡើងវិញក្នុងទំហំ ១,៤៦៥.៨៤ ហត ។

+ព្រៃលិចទឹក

ដែលមានទំហំប្រមាណ ៩៣០.៤១ ហិកតា ក្នុងតំបន់ដីសើមជាប្រភេទព្រៃរបោះដែលសំបូរទៅដោយឈើក្រញូីប ស្មាច់ តាប៊ុន កោងកាង អំពៅ មានសក្តានុពលភាពដ៏វិសាល សំរាប់ជំរកមច្ឆជាតិ ក្នុងការបន្តពូជ និង បំរើវិស័យទេសចធម្មជាតិផងដែរ ។

+ព្រៃកាប់ឆ្ការ

ជាប្រភេទព្រៃដែលប្រជាពលរដ្ឋបានកាប់ឆ្ការពង្រីកផ្ទៃដី ស្រែ ចំការ ក្បែរភូមិដ្ឋានទំហំ ៦៥.៧៥ ហត ។

+ព្រៃកោងកាងស្តើង ក្រាស់

មានទំហំសរុប ៣,១៩៥.៦៨ ហត ជាប្រភេទព្រៃដែលដុះតាមមាត់សមុទ្រ ព្រែក ឆ្នេរ ដែលមានជាតិទឹកប្រៃ ព្រៃកោងកាងមានសារៈសំខាន់ណាស់ជាជំរកសត្វស្លាប និង មច្ឆាជាតិ និង បំរើវិស័យទេសចរ ។

+វាលស្មៅ

នៅឃុំជ្រោយប្រស់មានវាលស្មៅទំហំ ៧៤៥.២៨ ហត សម្បូរទៅដោយ ស្បូវ ស្មៅកន្ទុយឆ្កែ កន្ត្រើយ ។ វាលស្មៅទាំងនេះងាយរងគ្រោះដោយសារភ្លើងឆេះនៅរដូវប្រាំង តែវាមានផលប្រយោជន៏

+ចំការបោះបង់ចោលដុះស្មៅ :

ក្នុងភូមិជ្រោយប្រស់រយៈពេលកន្លងមក មានប្រជាពលរដ្ឋបានកាប់ឆ្ការព្រៃយកដីដាំកញ្ឆាក្នុងកំឡុងឆ្នាំ ១៩៨៨-១៩៨៩ តែដោយច្បាប់លុបបំបាត់ការដាំ និង ផលិតគ្រឿងញៀន ក្រោយមកបានបន្សល់ដីចោលដុះស្មៅ ដែលមានទំហំ ៦.០០ ហត ។

+វាលស្មៅលិចទឹក :

មានទំហំ ២៩៧.៨៧ ហត សម្បូរទៅដោយស្មៅប្រភេទ កក់ អញ្ចូត មានផលប្រយោជន៏ដល់ប្រជាពលរដ្ឋ ក្នុងមូលដ្ឋានធ្វើកន្ទេល ។

+ព្រៃគុម្ពោត :

មានទំហំ៦៦២.៨៤ ហត ដែលសំបូរទៅដោយព្រៃពួច ញិញ គុយ ធ្លក ចំបក់ ប្រភេទព្រៃទាំងនេះមួយ ចំនួនក៏ផ្តល់ជាអាហាររបស់មនុស្សផងដែរ ។

+បឹង :

បឹងទាំងឡាយនៅក្នុងឃុំជ្រោយប្រស់មានទំហំ ៥៥.៨៨ ហត និង ជាកន្លែងផ្តល់ទឹកដល់សត្វទាំងឡាយ ( ផឹក ) ជាពិសេសនៅរដូវប្រាំង ជាពិសេសបឹងទាំងនេះសម្បូទៅដោយត្រីទឹកសាប ។

+សមុទ្រ :

ឃុំជ្រោយប្រស់ជាឃុំមួយនៅជាប់ និងសមុទ្រ ដែលមានទំហំ ១,៣៦៤.១៣ ហត នៅក្រោមការ ការពារ ដោយសហគមន៏នេសាទ ។ល។ ហើយផ្តល់នូវលទ្ធភាពដល់ប្រជាពលរដ្ឋក្នុងការធ្វើអាជីវកម្មនេសាទ ( លក្ខណៈ សាមញ្ញ ) ម្យ៉ាងទៀតជាផ្លូវគមនាគមន៏ដ៏សំខាន់សំរាប់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និង ដឹកជញ្ជូន ។

+នៅក្នុងឃុំជ្រោយប្រស់តាមមាត់ឆ្នេរ បាតសមុទ្រសំបូរទៅដោយខ្សាច់ ជាប្រភេទខ្សាច់ស ដែលមានទំហំ ១៣.៧៥ ហិកតា មានសារៈប្រយោជន៏ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក្នុងការសាងសង់ផ្សេងៗ ។

+ដីគ្មានជីជាតិដុះគ្របដណ្តប់

ដីប្រភេទនេះពុំសូវជាមានប៉ុន្មាននៅក្នុងឃុំជ្រោយប្រស់ គឺមានទំហំ ៦.៧២ ហិកតា ប៉ុណ្ណោះព្រោះដីគ្មាន ជីវជាតិ មានតែថ្ម ដីដាំទឹក ។

## ២,២ ផលិតភាពរបស់ដី (ផែនទី A.3)

| លរ | ចំណាត់ថ្នាក់ដីមានជីវជាតិ (តាមបច្ចេកទេស) | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|
| 1 |  Code : 1200<br>ដីលំនៅដ្ឋាន : ផ្ទះ-ទីសំណាប-ឈើហូបផ្លែ |  |
| 2 |  Code : 1210<br>ភូមិបណ្តែតទឹក: (ប្តូរនិមិត្តសញ្ញាឡើងវិញ) |  |
| 3 |  Code : 2110<br>ស្រូវវស្សា : ធ្វើស្រែវស្សា-ស្រែប្រាំង |  |
| 4 |  Code : 2120<br>ស្រូវឡើងទឹក : ស្រូវឡើងទឹក ស្រូវវារ |  |

| | | |
|---|---|---|
| 5 | Code : 2200<br>ចំការដំណាំ : ឈើហូបផ្លែ-ដំណាំរយៈពេល<br>ខ្លីពោត...-បន្លែគ្រប់មុខ |  |
| 6 | Code : 3500<br>ព្រៃលិចទឹក : |  |
| 7 | Code : 3510<br>ព្រៃលិចទឹកក្រាស់ : |  |
| 8 | Code : 4100<br>វាលស្មៅ : | |
| 9 | Code : 4200<br>វាលស្មៅលិចទឹក : | |
| 10 | Code : 5100<br>បឹង : |  |

| | | |
|---|---|---|
| 11 | Code : 5111<br>បឹងមានទឹកជាប្រចាំ : |  |
| 12 | Code : 5112<br>បឹងមានទឹកនៅរដូវវស្សា : |  |
| 13 | Code : 5211<br>ទន្លេ អូរ ស្ទឹង មានទឹកជាប្រចាំ : |  |

## ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិកតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត្ត និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចគ្រីនិរិច | សាធារណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | |
| | ដីលំនៅដ្ឋានភូមិ | ដីឯកជន | ២៩.២៥ |
| | ស្រែវស្សា | ដីឯកជន | ៣២២.៥២ |
| | ចំការឈើហូបផ្លែ | ដីឯកជន | ១២៥.១៩ |
| | កសិកម្មពនេចរ | ដីឯកជនរបស់រដ្ឋ | ១២០.២៥ |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ៩,៧៨២.៨៣ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ៥២៩.៥៤ |
| | ព្រៃលិចទឹក | ដីឯកជនរបស់រដ្ឋ | ១៧២ |
| | ព្រៃកោងកាង | ដីឯកជនរបស់រដ្ឋ | ៣៩១.៧៩ |
| | ព្រៃកោងកាងស្តើង | ដីឯកជនរបស់រដ្ឋ | ៦៧៧.៤៣ |
| | ល្បាយដីព្រៃលាយដីចំការ | ដីឯកជនរបស់រដ្ឋ | ១,០៨២.០០ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ៤៨៤.៦៦ |
| | វាលស្មៅលិចទឹក | ដីឯកជនរបស់រដ្ឋ | ១៦.៤៥ |
| | ព្រៃគុម្ពោត | ដីឯកជនរបស់រដ្ឋ | ៣០៦.១៩ |
| | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | ដីឯកជនរបស់រដ្ឋ | ៤៣.៨៨ |
| | បឹង | ដីឯកជនរបស់រដ្ឋ | ២.៦៨ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៦៨.៩១ |
| | ព្រៃកាប់ឆ្ការ | ដីឯកជនរបស់រដ្ឋ | ៦៥.៧៥ |
| ២ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចគ្រីនិរិច | សាធារណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | |
| | ស្រែវស្សា | ដីឯកជន | ១១.២១ |
| | ចំការដំណាំ | ដីឯកជន | ៧.៥៥ |
| | ចំការឈើហូបផ្លែ | ដីឯកជន | ១០.១៨ |

| | | | |
|---|---|---|---|
| | កសិកម្មពនេចរ | ដីឯកជនរបស់រដ្ឋ | ២៧៣.៥៣ |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ៨១០.៦៩ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ២២១.១៦ |
| | ព្រៃលិចទឹក | ដីឯកជនរបស់រដ្ឋ | ៣៤៩.១៥ |
| | ព្រៃកោងកាង | ដីឯកជនរបស់រដ្ឋ | ១,០៧៩.១៦ |
| | ព្រៃកោងកាងស្តើង | ដីឯកជនរបស់រដ្ឋ | ៦២.២៦ |
| | ល្បាយដីព្រៃលាយដីកសិកម្ម | ដីឯកជនរបស់រដ្ឋ | ១០២ |
| | ល្បាយដីព្រៃលាយដីចំការ | ដីឯកជនរបស់រដ្ឋ | ៣១៧.៦០ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ៩៦.០០ |
| | ចំការបោះបង់ចោលដុះស្មៅ | ដីឯកជនរបស់រដ្ឋ | ៧៦ |
| | វាលស្មៅលិចទឹក | ដីឯកជនរបស់រដ្ឋ | ២៨១.៤២ |
| | ព្រៃគុម្ពោត | ដីឯកជនរបស់រដ្ឋ | ១៦៣.១៨ |
| | ព្រៃគុម្ពោតលាយដើមឈើធំមួយៗ | ដីឯកជនរបស់រដ្ឋ | ៥១ |
| | បឹង | ដីឯកជនរបស់រដ្ឋ | ៥៣.២ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ១៣៣ |
| ៣ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ | សាធារណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | |
| | កសិកម្មពនេចរ | ដីឯកជនរបស់រដ្ឋ | ០.៧៩ |
| | ព្រៃស្រោង | ដីឯកជនរបស់រដ្ឋ | ១២,៥២៧.៤៥ |
| | ព្រៃដុះឡើងវិញ | ដីឯកជនរបស់រដ្ឋ | ៦៦.៧៤ |
| | ព្រៃកោងកាង | ដីឯកជនរបស់រដ្ឋ | ៤១១.៣៣ |
| | ព្រៃកោងកាងស្តើង | ដីឯកជនរបស់រដ្ឋ | ១០.៤ |
| | វាលស្មៅ | ដីឯកជនរបស់រដ្ឋ | ១១៣.៧៧ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ៨៩.៤២ |
| ៤ | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតក្នុងតំបន់ដែនជំរកសត្វព្រៃពាមក្រសោប | សាធារណៈរបស់រដ្ឋ-ឯកជនរបស់រដ្ឋ | |
| | ព្រៃកោងកាង | ដីឯកជនរបស់រដ្ឋ | ២៣៩.០០ |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | ១៨៥.៩ |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តកោះកុង

**ឧបសម្ព័ន្ធ ៣**

**បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី (បញ្ហា/មូលហេតុ/ដំណោះស្រាយ)**

| បញ្ហា | ទីតាំងនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| **ផលនេសាទថយចុះ** | ០២ ភូមិ | -ប្រើប្រាស់ឧបករណ៍ខុសច្បាប់<br>-បាត់បង់ព្រៃកោងកាង<br>-ប្រើថ្នាំពុល<br>-កំណើនអ្នកនេសាទ | -ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍<br>-ដាំដើមកោងកាងឡើងវិញ<br>-បង្កើនការដាំ និងចិញ្ចឹមឡើងវិញ<br>-ពង្រឹងសហគមន៍នេសាទ |
| **បាត់បង់ព្រៃ** | ០២ ភូមិ | -ការកាប់ព្រៃឈើចំការ<br>-ការកាប់ដីព្រៃយកដីធ្វើជាកម្មសិទ្ធិ<br>-ការដុតព្រៃធ្វើធ្យូង | -ទប់ស្កាត់ការកាប់ព្រៃរុករានយកដី<br>-បើកវគ្គបណ្តុះបណ្តាលធ្វើឧស្ម័នធម្មជាតិ ១៥ វគ្គ |
| **ដីខ្សោះជីវៈជាតិ** | ០២ ភូមិ | -ការហូរច្រោះដី | -បណ្តុះបណ្តាលបច្ចេទេសធ្វើជីកំប៉ុស្តិ៍ ១៥ វគ្គ<br>-បណ្តុះបណ្តាលធ្វើជី EM |
| **ខ្វះផ្លូវបេតុង** | ០២ ភូមិ | -ពិបាកធ្វើដំណើរក្នុងភូមិ | -សាងសង់ផ្លូវមេតុងប្រវែង ១.០៥ ម |
| **ធ្វើផ្លូវក្រាលគ្រួសក្រហម** | ពីឃុំទៅផ្លូវជាតិលេខ ៤៨ | -គ្មានផ្លូវគោកធ្វើដំណើរ | -សង់ផ្លូវលំក្រាលគ្រួសក្រហម ១ ខ្សែ ប្រវែង ២៧ គ.ម |
| **ប្រជាពលរដ្ឋមានជំងឺច្រើន** | ០២ ភូមិ | -គ្មានប៉ុស្តិ៍សុខភាព | -សង់ប៉ុស្តិ៍សុខភាព ១ ខ្នង |
| **ទិន្នផលស្រូវទាប** | ០២ភូមិ | -ខ្វះពូជស្រូវដែលមានទិន្នផលខ្ពស់ | -សូមផ្តល់ពូជស្រូវមានទិន្នផលខ្ពស់ ០១ តោន |
| **ខ្វះទឹកស្អាតប្រើប្រាស់** | ០២ ភូមិ | -ប្រជាពលរដ្ឋពុំទាន់យល់ច្បាស់ | -ផ្សព្វផ្សាយពីច្បាប់ភូមិបាល |

| | | | |
|---|---|---|---|
| | | | -ចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លី |
| **ស្ត្រីខ្វះការងារធ្វើ** | ០២ ភូមិ | -ស្ត្រីគ្មានវិជ្ជាជីវៈ | -បណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ |
| **អត្រានុកូលដ្ឋាន** | ០២ ភូមិ | -ប្រជាពលរដ្ឋមិនទាន់បានចុះគ្រប់គ្នា | -ផ្សព្វផ្សាយពីតំលៃអត្រានុកូលដ្ឋាន |
| **អំពើហឹង្សាក្នុងគ្រួសារ** | ០២ ភូមិ | -ភាពក្រីក្រ<br>-ល្បែងស៊ីសង<br>-គ្រឿងស្រវឹង | -ផ្សព្វផ្សាយច្បាប់អប់រំអំពើហឹង្សាក្នុងគ្រួសារ |
| **ទិន្នផលត្រីកាម៉ុង** | ០២ ភូមិ | -តំលៃទាប<br>-គ្មានទីផ្សា | -បង្កើតសិប្បកម្មកែច្នៃ<br>-ឡត្រីចំហុយ និងឡត្រីខ្នាតតូច |
| **កាកសំណល់ក្នុងឃុំ** | ទូទាំងឃុំ | -ប្រជាពលរដ្ឋខ្វះការយល់ដឹង | -ផ្សព្វផ្សាយអនាម័យ និង បរិស្ថាន<br>-ផ្សព្វផ្សាយសុខភាពមាតា និង ទារក |
| **ការជួញដូរស្ត្រីនិងកុមារ** | ទូទាំងឃុំ | -ជីវភាពខ្វះខាត<br>-ការយល់ដឹងនៅមានកំរិត | -ផ្សព្វផ្សាយច្បាប់ហាមឃាត់ការជួញដូរស្ត្រីនិងកុមារ ០២ វគ្គ |
| **អនុផលព្រៃឈើ** | ០២ ភូមិ | -គ្មានសិប្បកម្មកែច្នៃ | -បង្កើតសិប្បកម្មកែច្នៃអនុផលព្រៃឈើ |
| **បាត់បង់ជំរកមច្ឆាជាតិ** | ទូទាំងឃុំ | -នេសាទដោយប្រើឧបករណ៍មងខ្ញរ | -ផ្សព្វផ្សាយច្បាប់ជលផល ២ វគ្គ<br>-បោះបង្គោលបេតុងការពារស្មៅសមុទ្រ និងធ្វើប្រអប់បេតុង |
| **ជីវភាពខ្វះខាត** | ០២ ភូមិ | -ខ្វះបច្ចេកទេសដាំស្រូវ | -បណ្តុះបណ្តាលបច្ចេកទេសដាំស្រូវ |
| **ទឹកប្រៃហូរចូលស្រែ** | ០២ ភូមិ | -គ្មានទំនប់ទឹកប្រៃ | -ធ្វើទំនប់ទឹកប្រៃ ១ ខ្សែប្រវែង ៥ x ៣២ = ១០ ម |
| **សិស្សបោះបង់សាលា** | ០២ ភូមិ | -ជួយរកកំរៃដល់គ្រួសារ | -ផ្សព្វផ្សាយឱ្យសិស្សបានចូលរៀនគ្រប់ៗគ្នា ២ វគ្គ |
| **កង្វះបច្ចេកទេស** | ០២ ភូមិ | -កំណើនធនធានជលផល | -បណ្តុះបណ្តាលបច្ចេកទេសកែច្នៃផលនេសាទ ២ វគ្គ |

| | | | |
|---|---|---|---|
| **កង្វះការងារធ្វើ** | ០២ ភូមិ | -គ្មានវិជ្ជាជីវៈ | -បណ្តុះបណ្តាលការចិញ្ចឹមសត្វ ២ វគ្គ |
| **ផលដំណាំទាប** | ០២ ភូមិ | -ខ្វះបច្ចេកទេសដាំដំណាំ | -បណ្តុះបណ្តាលដាំដំណាំឈើហូបផ្លែ |
| **ការពារសុខភាពទារក** | ០២ ភូមិ | -ទារកមានជំងឺ | -យុទ្ធនាការចាក់ថ្នាំ ៧ មុខ |
| **ខ្វះគ្រូ** | ០២ ភូមិ | -ការយល់ដឹងនៅមានកំរិត | -ផ្សព្វផ្សាយសុខភាពបន្តពូជ<br>-ផ្សព្វផ្សាយពីជំងឺអេដស៍ |

## ឧបសម្ព័ន្ធ ៤

## ក្របខណ្ឌនៃការអភិវឌ្ឍន៍ និងជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើ ផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| មានការងារធ្វើ | CDP | -ចង់បានទិន្នផលខ្ពស់ | -ពង្រីកផ្ទៃដី និង បង្កើនការយល់ដឹងពី បច្ចេកទេស | -បណ្តុះបណ្តាលការងារកសិកម្ម ១៥ វគ្គ | |
| ចាក់ថ្នាំការពារ | CDP | ការពារជំងឺសត្វពាហនៈ | - ជំរុញប្រជាជនឱ្យចេះ ថែទាំសត្វពាហនៈ | -អន្តរាគមន៍ចាក់ថ្នាំការពារ សត្វពាហនៈ | |
| ឱ្យមានប័ណ្ណកម្មសិទ្ធិ | CDP | ចង់ឱ្យប្រជាពលរដ្ឋមានសិទ្ធិ កាន់កាប់ដីធ្លីស្របច្បាប់ | -រៀបចំផែនការធ្វើ ប័ណ្ណកម្មសិទ្ធិជូន ប្រជាពលរដ្ឋក្នុងឃុំ | -ចេញប័ណ្ណសំគាល់សិទ្ធិដីធ្លី | |
| ឱ្យយល់ដឹងពីតំលៃ អត្រានុកូលដ្ឋាន | CDP | -ចង់ឱ្យប្រជាពលរដ្ឋបានចុះ បញ្ជីអត្រានុកូលដ្ឋានគ្រប់ៗគ្នា | ចុះផ្សព្វផ្សាយពីតំលៃ នៃអត្រានុកូលដ្ឋាន | -ផ្សព្វផ្សាយពីតំលៃ អត្រានុកូលដ្ឋាន<br>-ជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន | |

| | | | | | |
|---|---|---|---|---|---|
| មានសណ្តាប់ធ្នាប់ក្នុងឃុំ | CDP | ចង់ឱ្យប្រជាពលរដ្ឋយល់ដឹងពីសណ្តាប់ធ្នាប់ និង ការរស់នៅក្នុងឃុំ | រៀបចំផ្សព្វផ្សាយពីការងារសន្តិសុខសណ្តាប់ធ្នាប់ | ពង្រឹងការងារសន្តិសុខក្នុងឃុំ | |
| ការពារព្រៃឈើ | CDP | ចង់ឱ្យប្រជាជនយល់ច្បាស់ពីតំលៃព្រៃឈើ | ជំរុញប្រជាជនឱ្យចេះការពារព្រៃឈើ | ការពារភ្លើងឆេះ | |
| ជំរកសត្វព្រៃ | CDP | ចង់ឱ្យសត្វព្រៃគង់វង្ស | ជំរុញប្រជាពលរដ្ឋឱ្យយល់ដឹងពីតំលៃ និង ចេះការពារសត្វព្រៃ | ផ្សព្វផ្សាយបញ្ហាភ្លើងឆេះព្រៃ | |
| ដាំដើមឈើឡើងវិញ | CDP | ចង់ឱ្យព្រៃឈើនៅគង់វង្ស និងមានលក្ខណៈដូចដើមវិញ | ផ្សព្វផ្សាយណែនាំដល់ប្រជាជនឱ្យចេះដាំដើមឈើ | ទប់ស្កាត់ការកាប់ព្រៃរុករានយកដី | |
| ឱ្យមានការអន្តរាគមន៍ | CDP | លប់បំបាត់សត្វល្អិតបំផ្លាញ | ជំរុញប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីការខូចខាតផលដំណាំកសិកម្មក្នុងឃុំ | អន្តរាគមន៍បាញ់ថ្នាំសំលាប់សត្វល្អិត | |
| ចង់ឱ្យជីវភាពគ្រួសារកើនឡើង | CDP | កាត់បន្ថយភាពក្រីក្រ | ជំរុញការយល់ដឹងរបស់ប្រជាពលរដ្ឋ | បង្កើតស្រ្តីសន្សំប្រាក់ | |

| | | | | | |
|---|---|---|---|---|---|
| | | | ពីការបង្កើតក្រុមស្ត្រីសន្សំប្រាក់ | | |
| មិនឱ្យមានទឹកប្រៃហូចូលស្រែ | CDP | ពង្រីកដីស្រែបង្កើនផលស្រូវ លើកកំពស់ប្រជាពលរដ្ឋក្នុងឃុំ | រៀបចំសាងសង់ទំនប់ការពារទឹកប្រៃហូរចូលស្រែ | ធ្វើទំនប់ការពារទឹកប្រៃ ១ ខ្សែ ប្រវែង ៥ ម គុណ ៣២១០ ម | |
| ចង់ឱ្យមានប៉ុស្តិ៍សុភាព | CDP | លើកកំពស់ និង បំរើសេវាសុខភាពជូនប្រជាពលរដ្ឋក្នុងឃុំ | រៀបចំសាងសង់ប៉ុស្តិ៍សុខភាពក្នុងឃុំ | សង់ប៉ុស្តិ៍សុខភាព១ខ្នង | |
| ចង់ចេះរបៀបថែទាំសុខភាព | CDP | លើកកំពស់ថែទាំសុខភាព | រៀបចំវគ្គបណ្តុះបណ្តាលពីរបៀបថែទាំសុខភាពក្នុងឃុំ | វគ្គបណ្តុះបណ្តាលពីការថែទាំសុខភាព ១៥ វគ្គ | |
| ចង់បានទឹកស្អាត | CDP | ចង់មានទឹកស្អាតកែប្រែជីវភាពប្រជាពលរដ្ឋក្នុងឃុំ | រៀបចំជីកអណ្តូងស្នប់ | ជីកអណ្តូងស្នប់ចំនួន ៧កន្លែង | |
| មានសុខភាពល្អ | CDP | ចង់ឱ្យប្រជាជនយល់ដឹងពីសេវាសុខភាព | រៀបចំផ្សព្វផ្សាយពីអនាម័យ បរិស្ថានក្នុងឃុំ | -អប់រំអនាម័យបរិស្ថានក្នុងឃុំ ១០ វគ្គ<br>-អប់រំផ្សព្វផ្សាយអនាម័យបរិស្ថានតាមសាលា ១០ វគ្គ | |
| ឱ្យមានការចូលរួមការពារ | CDP | ចង់ឱ្យធនធានជលផល | ជំរុញប្រជាពលរដ្ឋឱ្យ | -ពង្រីកនិងដំណើរការសហគមន៍ | |

| | | | | | |
|---|---|---|---|---|---|
| ធនធានជលផល | | កើនឡើង | ចេះច្បាប់ជលផលសហគមន៍ | គ្រប់គ្រងធនធានធម្មជាតិ<br>-ផ្សព្វផ្សាយច្បាប់ជលផល ១០ វគ្គ | |
| ការពារជំរកធម្មជាតិ | CDP | ចង់ឱ្យធម្មជាតិកើនឡើង | ជំរុញឱ្យប្រជាពលរដ្ឋចេះការពារធនធានធម្មជាតិ | ផ្សព្វផ្សាយច្បាប់ជលផល ១០ វគ្គ | |
| ឱ្យមានធម្មជាតិកើនឡើង | CDP | ចង់ឱ្យផលនេសាទកើនឡើង | បោះបង្គោលការពារស្មៅសមុទ្រ | ការពារស្មៅសមុទ្រ | |
| សុំឱ្យស្ត្រីមានវិជ្ជាជីវៈ | CDP | ចង់ឱ្យស្ត្រីមានការងារបន្ថែម | ឱ្យស្ត្រីមានវិជ្ជាជីវៈ | បណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រី | |
| មានសុភមង្គលក្នុងគ្រួសារ | CDP | ចង់ឱ្យយល់ដឹងច្បាប់អំពើហឹង្សា | ចុះផ្សព្វផ្សាយច្បាប់ជួញដូរស្ត្រី និង កុមារ | ផ្សព្វផ្សាយច្បាប់ហាមឃាត់ការជួញដូរស្ត្រីនិងកុមារ ១០ វគ្គ | |
| ចង់ឱ្យសិស្សចូលរៀន | CDP | ចង់ឱ្យសិស្សមានចំណេះដឹង | បើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយដល់អាណាព្យាបាលសិស្ស | រៀបចំបើកវគ្គផ្សព្វផ្សាយ | |

## ឧបសម្ព័ន្ធ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១[១] | ៥ឆ្នាំទី២[២] | ៥ឆ្នាំទី៣[៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ | 0 | 0 | 0 | 0 | 0 | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហមនិងជួសជុល ( ១ ខ្សែ ) | ២២.០៦៩ | គ.ម | ៧.៣៥៦ | ៧.៣៥៦ | ៧.៣៥៦ | |
| | ១.១.៣. ប្រវែងផ្លូវក្រាលដីស | ១,២៣៩ | គ.ម | 0.៤៤៥ | 0.៣៩៧ | 0.៣៩៧ | |
| | ១,១,៤ ប្រវែងផ្លូវបេតុង | 0.៥៥៥ | គ.ម | 0.២៥៥ | 0.២៥៥ | 0.៤៥ | |
| | ១,១,៥ ប្រវែងផែបេតុង | | | | | | |
| | ១,១,៦ ផ្លូវរទេះ/ថ្មើរជើង | | | | | | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ | ៣.២១០ | គ.ម | ១.៥៩៦ | ១.៥៩៦ | 0 | |

[១] - ៥ឆ្នាំទី១ (២០០៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

[២] - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

[៣] - ៥ឆ្នាំទី២ (២០១៨-២០២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.២.២. ប្រឡាយរង | ២.៧០០ | គ.ម | ១.១៣៩ | ១.៥៦១ | ០ | |
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | ៦ | កន្លែង | ២ | ២ | ២ | |
| | ១.៣.២. ចំនួនស្ពានឈើ | | | | | | |
| | ១.៣.៣. ចំនួន ទ្វារទឹក | ១ | កន្លែង | ១ | ០ | ០ | |
| | ១.៣.៤. ទំនប់ការពាទឹកប្រៃ | ៣.២១០ | គ.ម | ១.០៧៤ | ១.០៧៤ | ១.០៧៤ | |
| | ១.៣.៥. ចំនួនលូឆ្លងផ្លូវ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ០ | ០ | ០ | ០ | ០ | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ០១ | ខ្នង | ០ | ០ | ១ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ០ | ០ | ០ | ០ | ០ | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២,៦,១,៣,១ មណ្ឌលសុខភាព | ០ | ០ | ០ | ០ | ០ | |
| | ២,៦,១,៣,២, ប៉ុស្តិ៍សុខភាព | ០១ | កន្លែង | ១ | ០ | ០ | |
| | ២,៦,១,៣,៣ ស្រះទឹកស្អាត | | | | | | |
| | ២,៦,១,៣,៤ អណ្តូងទឹកស្អាត | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២,៦,១,៣,៥ កន្លែងចាក់សំរាម | | | 0 | | 0 | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៤.២. ទីផ្សារ | | | 0 | | 0 | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.២. វត្តអារាម | 0 | 0 | 0 | 0 | 0 | |
| | ២.៦.១.៥.៣. សាលាឆទាន | 0១ | កន្លែង | 0 | 0១ | 0 | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ឧទ្យានជាតិបូទុមសាគរ | ២៧,៤៣៧.៣៣ | ហិកតា | 0 | 0 | 0 | |
| | ២.៦.២.១.២. ដែនជំរកសត្វព្រៃពាមក្រសោប | ៤២៤.៩៧ | ហិកតា | 0 | 0 | 0 | |
| | ២.៦.២.១.៣. ក្រុហ៊ុនគ្រិនរិច | ១៨.៣៤២.៨៤ | ហិកតា | 0 | 0 | 0 | |
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ៩៥ | ហិកតា | ៥៤ | ២០.៥ | ២០.៥ | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | ១ | ហិកតា | ១ | 0 | 0 | |
| | ២.៦.២.២.៣. ដីវាលស្រែ | 0 | 0 | 0 | 0 | 0 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.២.៤. ដីស្រោចស្រព | 0 | 0 | 0 | 0 | 0 | |
| | ២.៦.២.២.៥. ដីចំការដំណាំហូបផ្លែ | ១២៧.៥ | ហិកតា | ៤៤.0២ | ៤២.៥២ | ៤២.៥២ | |
| | ២.៦.២.២.៦. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែ | | | | | | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដី | | | | | | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាល អំពីការកែប្រែគុណភាពដី | | | | | | |
| | ២.៦.២.៣.៤. ផ្សព្វផ្សាយច្បាប់ភូមិបាល+រដ្ឋបាលព្រៃឈើ,ជលផល | | | | | | |
| | ២,៦,៣,៣,៥ ផ្សព្វផ្សាយច្បាប់ភូមិបាល រដ្ឋបាលព្រៃឈើ | | | | | | |